# អប់រំ

# សមត្ថភាពចាំបាច់

## ដល់កុមារមត្តេយ្យសិក្សា និងសិស្សបឋមសិក្សា




ឆ្នាំ ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:...៤៣៥.....អយក.ប្រក

# ប្រកាស
# ស្ដីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# សៀវភៅ «អប់រំសមត្ថភាពចាំបាច់ដល់កុមារមត្តេយ្យសិក្សា និងសិស្សបឋមសិក្សា»
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្ដីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ពិនិត្យនិងវាយតម្លៃរបស់អ្នកវាយតម្លៃសៀវភៅ «អប់រំសមត្ថភាពចាំបាច់ដល់កុមារមត្តេយ្យសិក្សា និងសិស្សបឋមសិក្សា» ចុះថ្ងៃចន្ទ ៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ របស់គណៈកម្មការពិនិត្យ និងវាយតម្លៃសៀវភៅសិក្សាគោល និងសម្ភារៈឧបទេស
- យោងលិខិតលេខ០២/២០២១ ចុះថ្ងៃចន្ទ ៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹង ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ របស់អង្គការកែច្នៃស៊ាម និងការសិក្សានៅកម្ពុជា
- យោងលិខិតលេខ ០៤៤ អគ.អរ.អកស ចុះថ្ងៃព្រហស្បតិ៍ ៦រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានអប់រំ

## សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ **«អប់រំសមត្ថភាពចាំបាច់ដល់កុមារមត្តេយ្យសិក្សា និងសិស្សបឋមសិក្សា»** ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់គណៈកម្មការនិពន្ធនៃអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់នៅតាមសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំយុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលាបឋមសិក្សា សាលាមត្តេយ្យសិក្សា និងអង្គការកែច្នៃសំរាម និងការអប់រំនៅកម្ពុជា មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ចន្ទ ៣កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២១

**កន្លែងទទួល៖**
- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី " ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ២ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺជានាអប់រំពលរដ្ឋឱ្យមានលក្ខណៈពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា មនសិការស្នេហាជាតិ ព្រមទាំងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

ពាក្យចាស់លោកពោលថា «ពត់ដែកទាន់នៅក្ដៅ អប់រំនិងប្រៀនប្រដៅកូនចៅទាន់នៅក្មេង» មានន័យថា ការអប់រំសមត្ថភាពដល់កុមារ មានភាពងាយស្រួលខណៈដែលកុមារនៅតូច។

ដូចនេះការអប់រំកុមារលើផ្នែកសមត្ថភាព ត្រូវចាប់ផ្ដើមតាំងពីនៅតាមផ្ទះតាមរយៈឪពុកម្ដាយ នៅតាមសាលារៀន តាមរយៈគ្រូបង្រៀន ដែលផ្ដើមចេញពីសាលាមត្តេយ្យសិក្សា និងភូមិសិក្សាជាបន្តបន្ទាប់ ។

គោលបំណងចម្បងឯកសារនេះ គឺជាជំនួយសម្រាប់លោកគ្រូ អ្នកគ្រូក្នុងការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ និងបឋមសិក្សា។

**គណៈកម្មការចងក្រងឯកសារ**

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រី

ឯកឧត្តម បណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ

លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការ

ឯកឧត្តម បណ្ឌិត **អ៊ឹម កុច** រដ្ឋលេខាធិការ

លោកជំទាវ **ទន់ សារអ៊ឹម** អនុរដ្ឋលេខាធិការ

ឯកឧត្តម **ប្រាក់ កុសល** ប្រធាននាយកដ្ឋានអប់រំកុមារតូច

លោក **ង៉ោ ប៉េងឡុង** ប្រធាននាយកដ្ឋាន បណ្តុះបណ្តាលនិងវិក្រិតការ

លោក **ជោ គឹមហេង** ប្រធានអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា

លោកស្រី **យឹម ចាន់ស្រី** នាយិកាសាលាមត្តេយ្យសំមីសូលនៃអង្គការកែច្នៃសំរាម និង
ការសិក្សានៅកម្ពុជា

## គណៈកម្មការរៀបចំ

លោក **យិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

លោក **ជោ គឹមហេង** ប្រធានអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា

លោកស្រី **យឹម ចាន់ស្រី** នាយិកាសាលាមត្តេយ្យសំមីសូល

លោកស្រី **សេង សុវណ្ណា** នាយិការង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

លោក **ថៅ តុលា** គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រិតការខេត្តស្វាយរៀង

លោកស្រី **នៅ នារី** ទីប្រឹក្សាអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា

លោក **Reinhard Witzel** ទីប្រឹក្សាអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា

## គណៈកម្មការត្រួតពិនិត្យ

ឯកឧត្តម **ពុត សាមិត្ត** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ

ឯកឧត្តម បណ្ឌិត **ម៉ុក សារ៉ុម** អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ

ឯកឧត្តម **ប្រាក់ កុសល** ប្រធាននាយកដ្ឋានអប់រំកុមារតូច

ឯកឧត្តម បណ្ឌិត **ចាន់ សុភា** ប្រធាននាយកដ្ឋានបឋមសិក្សា

លោក **ង៉ោ ប៉េងឡុង** ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ

លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## ទីប្រឹក្សាបច្ចេកទេស

លោក **ជោ គឹមហេង** ប្រធានអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា

លោក Reinhard  Witzel ទីប្រឹក្សាអង្គការកែច្នៃសំរាមនិងការសិក្សានៅកម្ពុជា

# មាតិកា

ទំព័រ


**អារម្ភកថា** ............ I

**មាតិកា** ............ III

**១- សេចក្តីផ្តើម** ............ 1

**២- និយមន័យ និងគោលបំណងនៃការអប់រំ** ............ 3

២.១- និយមន័យពាក្យ អប់រំ ............ 3

២.២- គោលបំណងនៃការអប់រំ ............ 3

២.៣- គោលបំណងចម្បងនៃការអប់រំកុមារនៅមត្តេយ្យសិក្សា និងសិស្សបឋមសិក្សា ... 4

**៣- និយមន័យ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ............ 6**

៣.១- និយមន័យ ប្រើក្នុងវិស័យអប់រំ ............ 6

៣.២- និយមន័យទូទៅ ............ 7

**៤- គុណប្រយោជន៍និងប្រសិទ្ធភាព បំណិននិងចរិយាសម្បទា ............ 7**

៤.១- ស្រឡាញ់ការសិក្សាពេញមួយជីវិត ............ 8

៤.២- ចិត្តសុខភាព ............ 9

៤.៣- កាយសុខភាព ............ 10

៤.៤- ស្មារតីទទួលខុសត្រូវខ្ពស់ ............ 11

៤.៥- ឆ្លុះបញ្ចាំងខ្លួនឯង ទទួលការទិតៀនពីអ្នកដទៃ ............ 12

៤.៦ - ធ្វើការងារជាក្រុម ............ 12

៤.៧- ធ្វើការប្រាស្រ័យទាក់ទង ............ 15

៤.៨- ភាពជាអ្នកដឹកនាំ ............ 17

៤.៩- សហគ្រិនភាព............ 18

**៥- ជំនាញរឹង និងជំនាញទន់ ............ 19**

៥.១- និយមន័យជំនាញរឹង ............ 19

៥.២- និយមន័យជំនាញទន់ ............ 19

៥.៣- សមាសភាគជំនាញទន់ ............ 21

**៦- គុណប្រយោជន៍ជំនាញទន់សម្រាប់កុមាររៀននៅសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា ........................................ 25**
៦.១- កុមារមានចិត្តចង់ចេះ ចង់ដឹង និងស្រឡាញ់ការសិក្សា................................ 27
៦.២- កុមារមានចិត្តអត់ធ្មត់ ................................................................ 29
៦.៣- កុមារមានវិន័យលើខ្លួនឯង ........................................................ 30
៦.៤- កុមារជឿជាក់លើសមត្ថភាពខ្លួនឯង................................................ 32
៦.៥- កុមារចេះធ្វើការផ្ដេះបញ្ចាំងខ្លួនឯង ................................................ 34
៦.៦- កុមារចេះធ្វើកិច្ចការដោយខ្លួនឯង.................................................. 35
៦.៧- កុមារមានស្មារតីទទួលខុសត្រូវលើខ្លួនឯង ........................................ 38
៦.៨- កុមារចេះលើកទឹកចិត្តខ្លួនឯង ...................................................... 40
៦.៩- កុមារសេចេះធ្វើការសហការ ........................................................ 41
៦.១០- កុមារចេះធ្វើការប្រាស្រ័យទាក់ទង ................................................ 42
៦.១១- កុមារចេះយល់អារម្មណ៍អ្នកដទៃ ................................................ 44
៦.១២- កុមារទទួលការទិតៀន/ការរិះគន់ពីអ្នកដទៃ ...................................... 46
**៧- សមត្ថភាពអាជីពជាគ្រូបង្រៀន ................................................ 47**
**៨- វិធីសាស្ត្របង្រៀន តាមគោលវិធីគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល ........................................................ 48**
៨.១- គោលវិធីគ្រូមជ្ឈមណ្ឌល .............................................................. 49
៨.២- គោលវិធីសិស្សមជ្ឈមណ្ឌល.......................................................... 52
**៩- គំរូទម្រង់កិច្ចតែងការបង្រៀនតាមមុខវិជ្ជា ........................................ 59**
**១០- សង្ខេបខ្លឹមសាររបស់សៀវភៅ.................................................... 61**
**ឯកសារពិគ្រោះ ........................................................................ 62**

# ១- សេចក្តីផ្តើម

នៅក្នុងរយៈពេលជាង៤០ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងរិះរកគ្រប់មធ្យោបាយ ធានាប្រែក្លាយព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

សមិទ្ធផលសំខាន់ៗជាច្រើនស្តែងចេញពីការខិតខំប្រឹងប្រែងដំបូងរបស់ព្រះរាជាណាចក្រកម្ពុជា គឺកម្ពុជាបានចូលនិងក្លាយជាសមាជិកអាស៊ាន នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៩ បន្ទាប់មកជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។

ការចូលជាសមាជិកក្នុងតំបន់និងពិភពលោក គឺដើម្បីពង្រីកទីផ្សារ និងផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋ។ ដូច្នេះយើងត្រូវពង្រីកនូវកម្លាំងពលកម្មការងារឱ្យមានសមត្ថភាពរឹងមាំក្នុងការប្រកួតប្រជែងទីផ្សារការងារ ទាំងក្នុងនិងក្រៅស្រុក ព្រមទាំងអាចរស់នៅនិងបំពេញការងារជាមួយជាតិសាសន៍ខ្លួនឯង និងជាតិសាសន៍ដទៃប្រកបដោយសុខដុមនីយកម្មជាមួយគ្នាបាន។

មានតែចំណេះដឹង ឬ **វិជ្ជាសម្បទា** ទាំងផ្នែកភាសា លេខសាស្ត្រ ភាសាបរទេស ព្រមទាំងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ មិនទាន់ជាកត្តាសត្យានុម័តសម្រាប់គុណភាព ប្រសិទ្ធភាព និងភាពជោគជ័យក្នុងការប្រកួតប្រជែងទីផ្សារការងារក្នុងសតវត្សរ៍ទី២១បានដោយងាយនោះទេ។ ពលរដ្ឋម្នាក់ៗដាច់ខាតត្រូវព្យាយាមហាត់ហ្វឹកហ្វឺនអនុវត្តប្រើប្រាស់ចំណេះដឹងប្រកបដោយភាពប៉ិនប្រសប់ចេះធ្វើការវិភាគ ត្រិះរិះ ពិចារណា ដោះស្រាយបញ្ហាបានត្រឹមត្រូវ ទាន់ពេលវេលា និងទាន់សភាពការណ៍ ប្រកបដោយគំនិតច្នៃប្រឌិត និងបង្កើតថ្មី ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ព្រមទាំងធ្វើសេចក្តីសម្រេចចិត្តប្រកបដោយភាពឆ្លាតវៃ។ នៅក្នុងវិស័យអប់រំ សមត្ថភាពនេះមានឈ្មោះថា **បំណិនសម្បទា**។

ពលរដ្ឋចេះរស់នៅប្រកបដោយសុខដុមនីយកម្មក្នុងសង្គម ជាមួយអ្នកដទៃ ដោយសារពួកគេមានឥរិយាបថ ឬ **ចរិយាសម្បទា**ល្អ។ ចរិយាសម្បទានេះ ពលរដ្ឋម្នាក់ៗត្រូវតែមាននិងទទួលបានតាមរយៈការអប់រំពេញមួយជីវិត ដូចវិជ្ជាសម្បទា និងបំណិនសម្បទាដែរ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវចក្ខុវិស័យនិងគោលដៅនៃការអប់រំជានាឱ្យពលរដ្ឋក្លាយជាពលរដ្ឋមានសមត្ថភាពសតវត្សទី២១ ប្រកបដោយតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

ចំណែកឯគោលបំណងរបស់សៀវភៅនេះគឺបង្ហាញពី៖

- គុណប្រយោជន៍ និងប្រសិទ្ធភាពចរិយាសម្បទា៖
  - ពលរដ្ឋត្រូវការសិក្សាពេញមួយជីវិត ដែលជាតម្រូវការចាំបាច់ សម្រាប់គុណភាពជីវភាពរស់នៅប្រចាំថ្ងៃ និង
  - កុមារត្រូវការសម្រាប់ការសិក្សានៅសាលាមត្តេយ្យ ត្រៀមខ្លួនសម្រាប់ការសិក្សានៅភូមិសិក្សាបន្ត និងពេញមួយជីវិត។
- វិធីសាស្ត្រអប់រំចរិយាសម្បទាដល់កុមារនៅសាលាមត្តេយ្យសិក្សា និងបឋមសិក្សា
- គំរូទម្រង់កិច្ចតែងការបង្រៀនសាលាមត្តេយ្យសិក្សា ។

# ២- និយមន័យ និងគោលបំណងនៃការអប់រំ

## ២.១- និយមន័យពាក្យ អប់រំ

អប់រំជាអន្តរកម្មពីបុគ្គលម្នាក់ទៅលើបុគ្គលដទៃម្នាក់ ឬច្រើននាក់នៅទីកន្លែងដែលមានការរៀបចំតាមនិយាមគរុកោសល្យត្រឹមត្រូវ និងក្នុងបំណងគរុកោសល្យមួយច្បាស់លាស់។

ក្នុងបរិបទប្រទេសកម្ពុជា ការអប់រំជាការផ្តល់ចំណេះដឹងផង ហាត់ហ្វឹកហ្វឺនឱ្យពលរដ្ឋស្ទាត់ជំនាញ និងមានភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់ ឬអនុវត្តចំណេះដឹងផង ព្រមទាំងទូន្មានឱ្យពលរដ្ឋមានទម្លាប់រស់នៅជាមួយជាតិសាសន៍ខ្លួនឯង និងជាតិសាសន៍ដទៃក្នុងសង្គមប្រកបដោយសុខដុមនីយកម្មជាមួយគ្នា។

ជាទូទៅ អ្នកអប់រំដឹងច្បាស់ណាស់ថា ការអប់រំកុមារឱ្យមានចរិយាសម្បទាល្អមានភាពងាយស្រួល តែពេលកុមារនៅមានអាយុតិច កុមារនៅតូច ហើយត្រូវចាប់ផ្តើមពីឪពុកម្តាយ និងមត្តេយ្យសិក្សាឡើងទៅដូចពាក្យចាស់ពោលថា «ពត់ដែកទាន់នៅក្តៅ អប់រំនិងប្រៀនប្រដៅកូនចៅទាន់នៅក្មេង»។

កត្តាជះឥទ្ធិពលលើការងារអប់រំចរិយាសម្បទាកុមារមាន ឪពុកម្តាយជាអ្នកអាណាព្យាបាលកុមារ សាលារៀន និងសង្គមដែលកុមារកំពុងរស់នៅ។ ដូចនេះអង្គទាំងបីត្រូវតែឯកភាពគ្នា កំណត់គោលបំណងការអប់រំកុមារ ឯកភាពមួយច្បាស់លាស់។

## ២.២- គោលបំណងនៃការអប់រំ

គោលបំណងនៃការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺជាការធានាឱ្យពលរដ្ឋមានទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ឬជាការធានាបាននូវការ៖

- ផ្តល់ចំណេះដឹងដល់ពលរដ្ឋពេញមួយជីវិត សម្រាប់និងដើម្បីជាគុណប្រយោជន៍ មានការងារ មុខរបរល្អធ្វើ ជាប្រភពចំណូលផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃបានល្អ លើកស្ទួយសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ
- ហ្វឹកហាត់ឱ្យពលរដ្ឋមានភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់ចំណេះដឹងប្រកបដោយប្រសិទ្ធភាព ទាំងពេលសិក្សា និងពេលប្រកបមុខរបរចិញ្ចឹមជីវិត
- ទូន្មានប្រៀនប្រដៅពលរដ្ឋឱ្យមានបុគ្គលិកលក្ខណៈ ឥរិយាបថ ចរិយាល្អ រស់នៅក្នុងសង្គម ទាំងក្នុងជីវិតសិក្សានិងប្រកបមុខរបរប្រកបដោយសុខដុមនីយកម្មជាមួយគ្នា។

## ២.៣- គោលបំណងចម្បងនៃការអប់រំកុមារនៅមត្តេយ្យសិក្សា និង សិស្សបឋមសិក្សា

ក្រៅពីអប់រំឱ្យកុមារមានវិជ្ជាសម្បទា បំណិនសម្បទា គោលបំណងចម្បងនៃការអប់រំនៅមត្តេយ្យសិក្សា គឺជានាំឱ្យកុមារទទួលបាន៖

- ការអប់រំ និងការពង្រឹងបន្ថែមលើសមត្ថភាពចាំបាច់ដែលកុមារមានស្រាប់ និងសមត្ថភាពចាំបាច់ជាច្រើនទៀត ដែលកុមារត្រូវការសម្រាប់ការសិក្សា និងការរស់នៅក្នុងសង្គមនាពេលបច្ចុប្បន្ននិងពេលអនាគត។ សមត្ថភាពចាំបាច់ដែលកុមារត្រូវការសម្រាប់ការសិក្សា ត្រូវបានបកស្រាយនៅក្នុងជំពូកទី៦
- ការអប់រំកុមារឱ្យស្រឡាញ់ការសិក្សា ចូលចិត្តរៀននិងទៅរៀន ចង់ចេះចង់ដឹងអ្វីដែលថ្មីជាបន្តបន្ទាប់
- អប់រំកុមារឱ្យត្រៀមខ្លួនបានល្អក្នុងការរស់នៅ រៀន និងលេងជាមួយកុមារថ្មី មិត្តថ្មី មិនដែលស្គាល់ពីមុនមក។ល។

សមត្ថភាពដែលកុមារមានស្រាប់ ជាសមត្ថភាពដែលកុមារមានមុនចូលរៀននៅសាលាមត្តេយ្យសិក្សា ឬមុនចូលរៀនថ្នាក់ទី១សាលាបឋមសិក្សា ឬមុនកុមារចូលរៀនក្នុងភូមិសិក្សាបន្ត។ សមត្ថភាពដែលកុមារមានស្រាប់នេះតែងតែមិនដូចគ្នា អាស្រ័យទៅលើឥទ្ធិពលគ្រួសារ និងឥទ្ធិពលសង្គមទៅលើកុមារ។

កុមារស្រឡាញ់ការសិក្សា ចូលចិត្តរៀន ចង់ទៅរៀន លុះត្រាតែតម្រូវការ និងសមត្ថភាពកុមារមានស្រាប់ត្រូវបានគិតគូរ។ ឧទាហរណ៍ កុមារមិនចូលចិត្តទទួលការស្តីបន្ទោស តែសប្បាយចិត្ត កុមារត្រូវបានលើកទឹកចិត្ត ពេលកុមារធ្វើអ្វីមួយបានល្អ។ កុមារពេញចិត្តនឹងការសិក្សា ពេលកុមារទទួលបានចម្លើយលើរាល់សំណួរដែលកុមារសួរ និងចង់ដឹង។

ពេលកុមារចូលរៀនដំបូង កុមារដែលមានភាពក្លាហាន មានសមត្ថភាពសម្របខ្លួន មិនរើសអើង តែងតែមានភាពងាយស្រួលទទួលយកនិងរាប់អានមិត្តថ្មី ងាយរស់នៅក្នុងបរិស្ថានមួយដែលមិនស្គាល់ពីមុន។

ជាការពិតណាស់ មិនមែនកុមារទាំងអស់សុទ្ធតែក្លាហាន ងាយសម្របខ្លួនសហការរៀន លេងជាមួយកុមារ និងរស់នៅជាមួយមនុស្សដែលកុមារមិនដែលស្គាល់ពីមុនបានភ្លាមៗនោះទេ។ ដូចនេះសាលាត្រូវមានដំណោះស្រាយសម្រាប់កុមារទាំងអស់នេះ។

ដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយជាច្រើនទៀតដែលសាលាបាននិងកំពុងអនុវត្ត គឺមុនបើកបវេសនកាល សាលាបើកទ្វារសម្រាប់ឱ្យឪពុកម្តាយនាំកុមារឱ្យស្គាល់សាលា ស្គាល់មុខគ្រូ ស្គាល់បរិវេណជុំវិញសាលាជាមុន ឱ្យបានច្រើនដង។ នៅពេលកុមារចូលរៀនដំបូង បើចាំបាច់ត្រូវមានមនុស្សម្នាក់ ដែលកុមារស្គាល់ ឱ្យរង់ចាំនៅក្នុងសាលា នៅកន្លែងណាដែលកុមារមើលទៅឃើញរហូតដល់កុមារស៊ាំនឹងជីវិតរស់នៅថ្មីរបស់គាត់ មានទំនុកចិត្តលើគ្រូ មានមិត្តភក្តិថ្មី។ល។

កុមារដែលត្រៀមខ្លួនបានល្អ មុនពេលកុមារចូលរៀននៅមត្តេយ្យសិក្សា ឬបឋមសិក្សា តិចឬច្រើន កុមារត្រូវមានសមត្ថភាពចាំបាច់មួយចំនួនដូចជា ឯករាជ្យម្ចាស់ការជាបណ្តើរៗលើការងារសាមញ្ញដែលកុមារអាចធ្វើបាន ដូចជាចេះធ្វើអនាម័យខ្លួន ប្រើប្រាស់បង្គន់អនាម័យ លាងដៃនឹងសាប៊ូ ពាក់ស្បែកជើង រៀបចំកាបូបកាតាបមករៀន និងទៅផ្ទះវិញដោយខ្លួនឯង។ល។

ដើម្បីឱ្យកុមារអាចសហការ លេង និងរៀនជាមួយកុមារដទៃទៀតបាន កុមារត្រូវការសមត្ថភាពជាច្រើនទៀតរួមមាន ការប្រាស្រ័យទាក់ទង មិនរើសអើង អត់ធ្មត់។ល។

## ៣- និយមន័យ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា

ដោយសារពាក្យវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ជាពាក្យបច្ចេកទេសថ្មីក្នុងវិស័យអប់រំ ដូចនេះសម្រាប់អ្នកដែលមិនពាក់ព័ន្ធនឹងការងារអប់រំ ពិតជាត្រូវការឱ្យមានការពន្យល់អត្ថន័យពាក្យទាំងបីខាងលើនេះបានក្បោះក្បាយ។

ដើម្បីងាយស្រួលយល់អត្ថន័យនៃពាក្យទាំងបីនេះ យើងបែងចែកជានិយមន័យដែលប្រើក្នុងវិស័យអប់រំ និងនិយមន័យទូទៅ។

### ៣.១- និយមន័យ ប្រើក្នុងវិស័យអប់រំ

**វិជ្ជាសម្បទា:** ជាចំណេះដឹងដែលសិស្សានុសិស្សទទួលបានតាមរយៈការអប់រំ សិក្សា រៀនសូត្រ សម្រាប់ជាគុណប្រយោជន៍ដល់ការសិក្សានៅគ្រប់ភូមិសិក្សាជាបន្តបន្ទាប់ និងពេញមួយជីវិត។

**បំណិនសម្បទា:** ជាភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់ចំណេះដឹង ដែលសិស្សានុសិស្សទទួលបានតាមរយៈការអប់រំសិក្សារៀនសូត្រ ជាគុណប្រយោជន៍ និងប្រសិទ្ធភាពក្នុងការដោះស្រាយរាល់បញ្ហា និងកិច្ចការដែលគ្រូដាក់ឱ្យនៅគ្រប់ភូមិសិក្សាជាបន្តបន្ទាប់ និងពេញមួយជីវិត។

**ចរិយាសម្បទា:** ជាឥរិយាបថវិជ្ជមានដែលសិស្សានុសិស្សទទួលបានតាមរយៈការអប់រំ សិក្សារៀនសូត្រតាមភូមិសិក្សានីមួយៗ ជាគុណប្រយោជន៍ដល់បុគ្គល និងការធ្វើទំនាក់ទំនងក្នុងសង្គម ការសិក្សាក្នុងសាលា ទាំងពេលលេង សហការរៀនសូត្រ និងធ្វើកិច្ចការផ្សេងៗប្រកបដោយសុខដុមនីយកម្មជាមួយគ្នា។

## ៣.២- និយមន័យទូទៅ

ជាទូទៅគេស្គាល់ ពាក្យវិជ្ជាសម្បទា ជាចំណេះដឹង ឬសមត្ថភាពវិជ្ជាជីវៈ ឬចំណេះដឹងវិជ្ជាជីវៈ ឯបំណិនសម្បទា ជាជំនាញវិជ្ជាជីវៈ ឬបំណិនវិជ្ជាជីវៈ និងចរិយាសម្បទា ជាបុគ្គលិកលក្ខណៈ ចរិយានិងឥរិយាបថរបស់បុគ្គលម្នាក់ដូចនេះ៖

**វិជ្ជាសម្បទា:** ជាសមត្ថភាពវិជ្ជាជីវៈ ឬចំណេះដឹងវិជ្ជាជីវៈដែលពលរដ្ឋទទួលបានតាមរយៈការអប់រំ សិក្សា ស្វ័យសិក្សាពេញមួយជីវិត សម្រាប់យកទៅអនុវត្តក្នុងការប្រកបមុខរបរផ្សេងៗ ជាគុណប្រយោជន៍ក្នុងការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ។

**បំណិនសម្បទា:** ជាជំនាញវិជ្ជាជីវៈឬបំណិនវិជ្ជាជីវៈរបស់ពលរដ្ឋម្នាក់ៗក្នុងការអនុវត្តចំណេះដឹងប្រកបដោយភាពប៉ិនប្រសប់ ច្នៃប្រឌិត និងប្រសិទ្ធភាពការងារក៏ដូចជាការប្រឡងប្រជែងការងារទីផ្សារ។

**ចរិយាសម្បទា:** ជាឥរិយាបថ និងចរិយា ឬបុគ្គលិកលក្ខណសម្បត្តិរបស់ពលរដ្ឋម្នាក់ៗប្រកាន់ខ្ជាប់សម្រាប់ជាគុណប្រយោជន៍ រស់នៅក្នុងសង្គមប្រកបដោយសុខដុមនីយកម្មជាមួយអ្នកដទៃ។

# ៤- គុណប្រយោជន៍និងប្រសិទ្ធភាព បំណិននិងចរិយាសម្បទា

នៅក្នុងឯកសារ ក្របខណ្ឌកម្មវិធីសិក្សា ចំណេះទូទៅ និងអប់រំបច្ចេកទេសចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡា គឺធានាបានពលរដ្ឋមានសមត្ថភាពពេញ

លេញ រស់នៅក្នុងសតវត្សទី២១ ក្នុងនោះមាន៖

- **វិជ្ជាសម្បទា:** អក្សរសាស្ត្រ លេខសាស្ត្រ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍
- **បំណិនសម្បទា:** អនុវត្តចំណេះដឹងប្រកបដោយប្រសិទ្ធភាព គុណភាពខ្ពស់តាមរយៈការវិភាគ ត្រិះរិះ ពិចារណា ច្នៃប្រឌិត និងបង្កើតថ្មី ព្រមទាំងមានការប្រាស្រ័យទាក់ទងក្នុងការធ្វើការងារជាក្រុមបានល្អ
- **ចរិយាសម្បទា:** អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមរយៈចេះនិងស្រឡាញ់ការសិក្សាពេញមួយជីវិត មានចិត្ត និងសុខភាពល្អ មានភាពជាអ្នកដឹកនាំ និងសហគ្រិនភាព។

ខាងក្រោមនេះជាការបកស្រាយពីគុណប្រយោជន៍ និងប្រសិទ្ធភាព បំណិនសម្បទា និងចរិយាសម្បទា សម្រាប់ជីវិតជោគជ័យ និងគាប់ចិត្តក្នុងការរស់នៅក្នុងសតវត្សទី២១។

## ៤.១- ស្រឡាញ់ការសិក្សាពេញមួយជីវិត

សិក្សាពេញមួយជីវិត ជាសមត្ថភាពបុគ្គលគ្រប់រូបត្រូវមានសម្រាប់ទទួលបាននូវចំណេះដឹងថ្មីៗ ដែលជាតម្រូវការសម្រាប់ជីវិតរស់នៅជាប្រចាំ សម្របខ្លួនបានល្អ និងទាន់ពេលវេលាលើរាល់ស្ថានភាពទាំងឡាយដែលកើតមានឡើងជាបន្តបន្ទាប់ក្នុងសង្គម។

សិក្សាពេញមួយជីវិត កើតឡើងមកពីការចង់ចេះចង់ដឹងជាបន្តបន្ទាប់ តាមរយៈការស្ម័គ្រចិត្ត និងការផ្តល់កម្លាំងចិត្តខ្លួនឯង ឯករាជ្យម្ចាស់ការ ព្រមទាំងក្នុងគោលបំណងមួយច្បាស់លាស់។

ការសិក្សាពេញមួយជីវិតផ្តល់នូវគុណប្រយោជន៍ឱ្យពលរដ្ឋជាច្រើនដូចជា៖

- អភិវឌ្ឍ ពង្រឹង ដុសខាត់ចំណេះដឹង ជំនាញ ព្រមទាំងសមត្ថភាពរបស់ខ្លួន បន្ថែមជាបន្តបន្ទាប់សម្រាប់ប្រសិទ្ធភាព គុណភាពការងារ និងជីវិតរស់នៅ
- បង្កើនសមត្ថភាពនិងគុណភាព ប្រឡងប្រជែងទីផ្សារការងារ បន្តភាពជោគជ័យលើការប្រកបមុខរបរចិញ្ចឹមជីវិត
- ស្វែងរកគន្លឹះសម្រាប់ដោះស្រាយបញ្ហាបានត្រឹមត្រូវ ទាន់ពេលវេលា និងទាន់សភាពការណ៍ ប្រកបដោយគំនិតច្នៃប្រឌិត និងបង្កើតថ្មី ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- មានឱកាសការងារកាន់តែល្អប្រសើរជាងមុន នាំឱ្យជីវិតរស់នៅកាន់តែមានគុណភាពខ្ពស់។ល។

ដើម្បីអភិវឌ្ឍន៍ និងពង្រឹង ព្រមទាំងដុសខាត់បន្ថែមលើចំណេះដឹង ជំនាញ ព្រមទាំងសមត្ថភាពផ្សេងទៀត យើងអាចធ្វើឡើងបានតាមរយៈការសិក្សា ស្វ័យសិក្សា ការស្រាវជ្រាវ ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗជាបន្តបន្ទាប់។ល។

បុគ្គលដែលអាចបន្តការសិក្សាបានជាបន្តបន្ទាប់បាន ដោយសារបុគ្គលនោះចេះមានការអត់ធ្មត់ ចេះចាត់ចែងពេលវេលាបានត្រឹមត្រូវ ទ្រាំទ្រនូវភាពតានតឹងនិងគ្រប់គ្រងលើខ្លួនឯងបានល្អ មានភាពឯករាជ្យម្ចាស់ការក្នុងការធ្វើសេចក្តីសម្រេចចិត្ត មានការទទួលខុសត្រូវខ្ពស់ ចេះធ្វើទំនាក់ទំនងសង្គម មានការប្រាស្រ័យទាក់ទងបានល្អ។ល។

## ៤.២- ចិត្តសុខភាព

ចិត្តសុខភាព មិនមែនសុខភាពផ្លូវចិត្តទេ តែមានទង្វើទៅលើគ្នាទៅវិញទៅមក។ ឧទាហរណ៍ៈ បើឪពុកម្នាក់មានចិត្តសុខភាពល្អ ប្រពន្ធ កូន និងសមាជិកក្នុងគ្រួសារពិតជាមានសេចក្តីសុខផ្លូវចិត្តជាមិនខាន។

ពលរដ្ឋដែលមានចិត្តសុខភាពល្អ៖

- មានភាពងាយស្រួលក្នុងការរស់នៅប្រកបដោយសុខដុមនីយកម្មជាមួយអ្នកដទៃក្នុងសង្គម
- មានឱកាសច្រើនក្នុងស្វែងរកការងារល្អៗធ្វើ និងងាយទទួលបានតួនាទីការងារ
- អាចអភិវឌ្ឍសមត្ថភាពខ្លួន ក្លាយជាថ្នាក់ដឹកនាំបានទៀតផង។ល។

ពលរដ្ឋដែលមានចិត្តសុខភាពល្អ សង្គមឱ្យតម្លៃខ្លាំងណាស់ ដោយសារគាត់ជាពលរដ្ឋមានសមត្ថភាពចាំបាច់ជាច្រើនទៀត រួមមានភាពស្មោះត្រង់ យល់អារម្មណ៍អ្នកដទៃ ចេះគោរពឱ្យតម្លៃលើខ្លួនឯងផង និងគោរពឱ្យតម្លៃអ្នកដទៃផង បើកបេះដូងទទួលការទិតៀនពីអ្នកដទៃ ចេះធ្វើការពិចារណាបានល្អិតល្អន់ មុននឹងធ្វើការសម្រេចចិត្តធ្វើអ្វីមួយ ជៀសវាងបាននូវរាល់ទង្វើដែលនាំឱ្យប៉ះពាល់ទៅនឹងចិត្តនិងអារម្មណ៍ ព្រមទាំងប្រយោជន៍អ្នកដទៃ។

## ៤.៣- កាយសុខភាព

ដូចគ្នានឹងចិត្តសុខភាព កាយសុខភាព មិនមែនសុខភាពផ្លូវកាយទេ តែមានទង្វើទៅលើគ្នាទៅវិញទៅមក។ ឧទាហរណ៍ៈ បើឪពុកម្នាក់មានកាយសុខភាពល្អ មិនមានអំពើហឹង្សាទៅលើ ប្រពន្ធ កូន សមាជិកក្នុងគ្រួសារពិតជាមានសេចក្តីសុខផ្លូវកាយជាមិនខាន។

ពលរដ្ឋក្នុងសង្គមមួយដែលពោរពេញទៅដោយសមត្ថភាព កាយសុខភាព សាមគ្គីភាព ភាតរភាពនឹងកើតមានឡើងជាមិនខាន ធ្វើឱ្យសង្គមដែលមានភាពរឹងមាំឡើងវិញ ប្រៀបធៀបដូចចង្កឹះមួយបាច់គ្មានអ្នកផ្សេងណាម្នាក់មកកាច់បំបាក់បានឡើយ។

ពលរដ្ឋក្នុងសង្គមមួយដែលពោរពេញទៅដោយសមត្ថភាពនេះ តែងតែមានឆន្ទៈមើលការខុសត្រូវគ្នាទៅវិញទៅមក។

ដូចចិត្តសុខភាពដែរ កាយសុខភាព ជាសមត្ថភាពចាំបាច់សម្រាប់ថ្នាក់ដឹកនាំត្រូវមាន។

ពលរដ្ឋមានកាយសុខភាពល្អតែងតែ៖

- មានឆន្ទៈ និងត្រៀមខ្លួនបានល្អជានិច្ច ចូលរួមរាល់សកម្មភាព និងការងារក្នុងសង្គម
- ចេះបង្កើត និងរក្សាចំណងមិត្តភាពបានយូរអង្វែង រាប់អានអ្នកដទៃដូចជាបងប្អូន មិនរើសអើង ចេះជួយគ្នាទៅវិញទៅមក
- មានឆន្ទៈក្នុងការចែករំលែក និងលះបង់ខ្ពស់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត។ល។

## ៤.៤- ស្មារតីទទួលខុសត្រូវខ្ពស់

ពលរដ្ឋម្នាក់មានស្មារតីទទួលខុសត្រូវខ្ពស់៖

- តែងតែគោរពពាក្យសន្យា ដោយធ្វើអ្វីដែលខ្លួនបាននិយាយ និងព្យាយាមដោះស្រាយបញ្ហាដែលខ្លួនប្រឈមក្នុងជីវិតប្រចាំថ្ងៃ
- មានបំណងនិងចេតនាធ្វើការកែតម្រូវ កែលម្អខ្លួនឯងឡើងវិញ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង
- ត្រៀមខ្លួនសម្រាប់កិច្ចសហប្រតិបត្តិការ ដោយប្រកាន់ខ្ជាប់នូវស្មារតីចូលរួមទទួលខុសត្រូវបានខ្ពស់
- ចេះធ្វើការឆ្លុះបញ្ចាំងខ្លួនឯង បើកបេះដូងទទួលការទិតៀនពីអ្នកដទៃ។ល។

ហេតុអ្វីយើងម្នាក់ៗ ត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីទទួលខុសត្រូវឱ្យបានខ្ពស់ជានិច្ច៖

- ទទួលបានការស្រឡាញ់រាប់អានយូរអង្វែងពីមនុស្សគ្រប់រូប ព្រោះគេមានភាពជឿជាក់លើយើង។ កាលណាយើងមានស្មារតីទទួលខុសត្រូវខ្ពស់ យើងតែងតែព្យាយាមដោះស្រាយបញ្ហាដែលខ្លួនប្រឈម ហ៊ានសារភាពកំហុស និងមានឆន្ទៈក្នុងការកែប្រែ

- ទទួលបានការយកចិត្តទុកដាក់ និងលើកទឹកចិត្តពីថ្នាក់ដឹកនាំ ងាយមានឱកាសទទួលបានតួនាទីការងារទៀតផងដែរ។ល។

## ៤.៥- ឆ្លុះបញ្ចាំងខ្លួនឯង ទទួលការទិតៀនពីអ្នកដទៃ

ឆ្លុះបញ្ចាំងខ្លួនឯងក៏ដូចជាទទួលការទិតៀនពីអ្នកដទៃ ជាកញ្ចក់សម្រាប់ឱ្យយើងអាចគិតគូរ និងត្រិះរិះពិចារណាយ៉ាងម៉ត់ចត់ ល្អិតល្អន់ទៅលើរាល់បទពិសោធន៍ដែលខ្លួនយើងបានធ្វើកន្លងមក។

ធ្វើការតិទៀនដល់អ្នកដទៃ និងទទួលការទិតៀនពីអ្នកដទៃត្រូវធ្វើឡើងតែក្នុងបំណងនិងជាគុណប្រយោជន៍សម្រាប់៖

- ធ្វើការនិងជួយតម្រង់ទិស ទាំងការរស់នៅ ទាំងការងារគ្រប់សារពើឱ្យទៅតាមទស្សនៈត្រឹមត្រូវមួយ សម្រេចនូវគុណភាព គោលដៅការរស់នៅ និងការងារ ដែលយើងបានគ្រោងទុក

- ពង្រឹងសមត្ថភាពគ្រប់គ្រងពេលវេលា និងដោះស្រាយបញ្ហា ប្រកបដោយប្រសិទ្ធភាព។ល។

## ៤.៦ - ធ្វើការងារជាក្រុម

ទាំងសម្រាប់ជីវិតការសិក្សា នៅកន្លែងប្រកបមុខរបរ និងការរស់នៅ ចេះធ្វើការងារជាក្រុម ជាសមត្ថភាពសំខាន់ដែលពលរដ្ឋទាំងអស់ត្រូវមានខានមិនបាន។

បុគ្គលដែលមានសមត្ថភាពនេះ ដឹងច្បាស់ណាស់ថាអ្វីដែលហៅថា ភារកិច្ច និងការទទួលខុសត្រូវ កិច្ចសហការ និងប្រាស្រ័យទាក់ទង។

ការងារជាក្រុម ដែលភាសាអង់គ្លេសគេហៅថា Teamwork ជាការឯកភាពពីមនុស្សមួយក្រុម លះបង់ ខិតខំប្រឹងប្រែង សហការបំពេញការងារជាមួយគ្នា ដើម្បីសម្រេចបាននូវគោលដៅរួមមួយប្រកបដោយប្រសិទ្ធភាព។

ការងារជាក្រុម តែងតែផ្តល់នូវគុណប្រយោជន៍ជាច្រើន ទាំងក្នុងជីវភាពរស់នៅ និងទាំងនៅកន្លែងធ្វើការងារដូចជា៖

- ក្នុងរយៈពេលខ្លី ធ្វើកិច្ចការបានកាន់តែច្រើន ប្រកបដោយប្រសិទ្ធភាព និងគុណភាព
- បណ្តុំគំនិតនិងសមត្ថភាពច្រើនចូលគ្នា អាចឱ្យយើងដោះស្រាយបញ្ហាមួយបានប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា
- គំនិតច្នៃប្រឌិត របស់សមាជិកក្រុមគ្រប់ៗគ្នាត្រូវបានបណ្តុះនិងពង្រឹងបន្ថែម
- បង្កឱកាសឱ្យសមាជិកក្រុមអាចរៀនសូត្របន្ថែមពីគ្នាទៅវិញទៅមក បង្កើននិងពង្រឹងចំណេះដឹង ព្រមទាំងសមត្ថភាពសម្រាប់ជាប្រយោជន៍អាជីពរបស់ខ្លួនបន្ត
- លើកទឹកចិត្តសមាជិកក្រុមការងារ ឱ្យមានឆន្ទៈខិតខំបញ្ចេញ និងប្រើប្រាស់សមត្ថភាព ទេពកោសល្យរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំពេញការងារមួយបានគ្រប់ជ្រុងជ្រោយដោយគ្មានភាពថ្លោះធ្លោយ។
- លទ្ធផលការងារដែលក្រុមទទួលបានជាលទ្ធផលក្រុមទាំងមូល មិនមែនជាលទ្ធផលរបស់នរណាម្នាក់។ បើសមាជិកក្រុមម្នាក់អសកម្ម ការងារជាក្រុមទាំងមូលក៏អសកម្ម ហើយចង្វាក់ផលិតកម្មនឹងមានឧបសគ្គ។ បើមាន

សមាជិកក្រុមតែម្នាក់ធ្វេសប្រហែស ប្រសិទ្ធភាពគុណភាពការងារទាំងមូល នឹងធ្លាក់ចុះ ហើយគោលដៅរួមនឹងមិនទទួលបានលទ្ធផលល្អ។ល។

បើនៅក្នុងស្ថាប័នមួយ ជាពិសេសក្នុងក្រុមហ៊ុន ការងារជាក្រុមទទួលបានជោគជ័យ នាំឱ្យក្រុមហ៊ុនក៏ជោគជ័យ ម្ចាស់ក្រុមហ៊ុនមិនត្រឹមតែមានការរីកចម្រើនថែមទាំងទទួលបានបុគ្គលិកមានសមត្ថភាពនិងមានភក្ដីភាពជាមួយក្រុមហ៊ុនទៀតផង។

គោលការណ៍មូលដ្ឋានសំខាន់ៗដែលមានប្រសិទ្ធភាពនិងគុណភាពសម្រាប់ការងារជាក្រុម៖

- សមាជិកក្រុមការងារ ត្រូវយល់ដូចៗគ្នាពីវត្ថុបំណងរួមរបស់ការងារជាក្រុម និងយល់ពីតួនាទី ភារកិច្ចរបស់ខ្លួនឯង ព្រមទាំងរបស់សមាជិកក្រុមទាំងមូល។ ដើម្បីយល់ពីវត្ថុបំណងរួម ភារកិច្ច និងតួនាទីរបស់ការងារជាក្រុម សមាជិកក្រុមការងារទាំងមូល ត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នាជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព តាំងពីចាប់ផ្ដើមចងក្រងជាក្រុម រៀបចំផែនការសកម្មភាព អនុវត្តផែនការសកម្មភាព និងការវាយតម្លៃលទ្ធផលការងារចុងក្រោយ។

- ពេលធ្វើការងារជាក្រុម សមាជិកក្រុមការងារទាំងអស់មានតម្លៃ និងត្រូវឱ្យតម្លៃស្មើៗគ្នា មិនគិតថានរណាមានតួនាទីជាអ្វីនៅក្នុងស្ថាប័ន។ ក្រៅពីមានភារកិច្ចនិងការទទួលខុសត្រូវបំពេញដូចសមាជិកក្រុមការងារដទៃ ប្រធានក្រុមការងារជាអ្នកសម្របសម្រួលការងារ ជានាឱ្យសមាជិកក្រុមសហការបំពេញការងារទទួលបានតាមវត្ថុបំណងរួមដែលរំពឹងទុក។

- សមាជិកក្រុមការងារទាំងអស់ត្រូវមានទឹកចិត្តនិងឆន្ទៈដូចគ្នាក្នុងការចូលរួមនិងសហការធ្វើការជាធ្លុងមួយ គ្មានការរើសអើង និងចេះជួយគ្នាទៅវិញមក។

- កត្តាដែលនាំឱ្យបរិយាកាសការងារក្នុងក្រុមបានល្អ សំខាន់គឺតម្លាភាពក្នុងក្រុម។ រាល់ព័ត៌មាននិងដំណឹងដែលទាក់ទងការងារជាក្រុម សមាជិកក្រុមការងារត្រូវទទួលបាននិងដឹងឮទាំងអស់គ្នាជានិច្ច។ មានកត្តាជាច្រើនទៀតដែលនាំឱ្យបរិយាកាសការងារក្នុងក្រុមល្អ ដូចជាសមាជិកក្រុមទាំងអស់ត្រូវមានកាយសុខភាព (សាមគ្គីភាពនិងភាតរភាព) ចិត្តសុខភាព (ស្មោះត្រង់ គុណធម៌ និងយល់អារម្មណ៍អ្នកដទៃ) បើកចិត្តទូលាយទទួលយកមតិយោបល់ត្រឡប់ និងមតិទិតៀនពីសហការីរបស់ខ្លួន។ ការសរសើរនិងលើកទឹកចិត្តគ្នាទៅវិញទៅមក ជាឱសថដ៏សក្តិសិទ្ធនាំឱ្យមនុស្សមានកម្លាំងកាយនិងចិត្ត លះបង់ខ្ពស់ក្នុងការបំពេញការងារ។

## ៤.៧- ធ្វើការប្រាស្រ័យទាក់ទង

ប្រាស្រ័យទាក់ទងមួយកើតឡើងតាមរយៈ (១)សំណេរដែលសព្វថ្ងៃគេកំពុងពេញនិយមប្រើប្រាស់តាមបណ្តាញសង្គម។ (២)ប្រើសញ្ញាតាង ដូចជាសញ្ញាចរាចរ ឬសញ្ញាតាងផ្សេងៗទៀត (៣)និយាយសន្ទនាផ្ទាល់មាត់ និង(៤)ប្រើកាយវិការ។

ប្រាស្រ័យទាក់ទង ដែលលើកមកនិយាយនៅក្នុងឯកសារនេះ គឺប្រាស្រ័យទាក់ទងជាក្រុមនិងផ្ទាល់មាត់។

យើងដឹងទាំងអស់គ្នាហើយថា ការងារជាក្រុមនឹងដំណើរការទៅដោយរលូនបាន លុះត្រាតែរាល់សមាជិកក្នុងក្រុមទាំងអស់ចេះផ្តល់ព័ត៌មាន និងធ្វើបច្ចុប្បន្នភាពគ្នាទៅវិញទៅមក តាមរយៈការប្រាស្រ័យទាក់ទងគ្នាជាប់ជានិច្ច។

មុនពេលដៃគូសន្ទនា ធ្វើការប្រាស្រ័យទាក់ទងគ្នា ម្នាក់ៗគួត្រូវដឹងថា៖

- អ្វីដែលយើងបាននិយាយទៅដៃគូសន្ទនា មិនច្បាស់ថាដៃគូសន្ទនាបានស្តាប់ទាំងអស់នោះទេ

- អ្វីដែលដៃគូសន្ទនាបានស្តាប់ហើយ មិនច្បាស់ថាគាត់បានយល់គ្រប់ជ្រុងជ្រោយ ទាំងអស់នោះទេ

- អ្វីដែលដៃគូសន្ទនាបានយល់ពីអ្វីដែលយើងចង់និយាយ បកស្រាយហើយ មិនទាន់ច្បាស់ថា តើដៃគូសន្ទនាឯកភាពឬអត់

- បើដៃគូសន្ទនាឯកភាពហើយ មិនទាន់ច្បាស់ទៀតថា តើដៃគូសន្ទនាយកទៅអនុវត្តឬអត់។ ដូច្នេះរាល់ការសន្ទនាជាផ្លូវការ តម្រូវឱ្យមានការធ្វើកំណត់ហេតុ រហូតដល់ជាលិខិតបទដ្ឋានផ្សេងៗ ដូចកិច្ចព្រមព្រៀង ដោយមានការចុះហត្ថលេខាទទួលស្គាល់ពីដៃគូសន្ទនាទាំងអស់។

ពេលសន្ទនាដៃគូទាំងអស់ត្រូវគោរពគោលការណ៍ចម្បងមួយចំនួន ដូចជាៈ

- បង្កើតភាពស្និទ្ធស្នាលមុនពេលការសន្ទនាជាផ្លូវការចាប់ផ្តើម ដែលជាបច្ច័យបង្កឱ្យដៃគូសន្ទនាហ៊ាននិយាយដោយចំហ ហ៊ានសួរសំណួរ និងបង្កើតចម្ងល់។ល។

- ដៃគូសន្ទនាត្រូវគោរពគោលការណ៍៥០% (និយាយ៥០% និងស្តាប់ ៥០%)

- ពេលត្រងត្រាប់និងស្តាប់ យើងត្រូវយកចិត្តទុកដាក់ចាប់យកខ្លឹមសារដៃគូបកស្រាយ ដោយមិនបញ្ចេញនូវឥរិយាបថណាដែលនាំឱ្យរំខានពេលដៃគូសន្ទនាកំពុងនិយាយនិងបកស្រាយឡើយ។ ការរៀបចំឥរិយាបថបានល្អ នៅពេលត្រងត្រាប់និងស្តាប់ លុះត្រាតែយើងមានវិន័យនិងគ្រប់គ្រងអារម្មណ៍ខ្លួនឯងបានល្អ មានចិត្តអត់ធ្មត់ ទោះជាពេលខ្លះយើងមិនពេញចិត្តក្នុងប្រការណាមួយ មិនត្រូវនិយាយកាត់ដៃគូសន្ទនា បើមិនចាំបាច់។ លើកទឹកចិត្ត ដៃគូសន្ទនា ផ្តល់ឱកាសក្នុងការបកស្រាយក៏ជាសមត្ថភាពសំខាន់ដែរ សម្រាប់ប្រសិទ្ធភាពប្រាស្រ័យទាក់ទងផងដែរ។

- ពេលនិយាយបកស្រាយទៅកាន់គូសន្ទនា យើងត្រូវប្រើឃ្លាឃ្លោង ពាក្យពេចន៍សាមញ្ញ និងងាយយល់ ជៀសវាងឱ្យបានរាល់ការបូរបាច់រឿងរ៉ាវឥតប្រយោជន៍ច្រើន នាំឱ្យគូសន្ទនាមានការធុញទ្រាន់។ ចរិតអួតអាង គួរត្រូវទុកនៅដោយឡែកនៅពេលសន្ទនា តែត្រូវមានភាពជឿជាក់លើសមត្ថភាពខ្លួនឯង ដោយមានអំណះអំណាងត្រឹមត្រូវ បើមិនដូច្នោះទេ ដៃគូសន្ទនានឹងបាត់បង់ជំនឿលើយើងជាមិនខាន។
- ពេលសន្ទនា ដៃគូសន្ទនាទាំងសងខាងត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់កាយវិការ ទឹកមុខ និងសញ្ញាណផ្សេងៗ។ ក្រៅពីអាចនាំឱ្យមានការរំខានក្នុងកិច្ចសន្ទនា ភាសាកាយវិការនិងសញ្ញាណអាចបង្ហាញបញ្ជាក់ពីអារម្មណ៍របស់មនុស្សម្នាក់បានដែរ ឧទាហរណ៍ៈ ពេលសន្ទនាដៃគូរវល់មើលទូរសព្ទក្រឡេកមើលតាមបង្អួចចេញទៅក្រៅយ៉ាងរំភើយ និងជដែកគ្នា។ល។
- សង្ខេបខ្លឹមសារការសន្ទនាឡើងវិញ ជាគោលការណ៍សំខាន់ណាស់ដែលដៃគូសន្ទនាត្រូវមានឱកាសដើម្បីបញ្ជាក់ថាតើខ្លឹមសារដែលបានស្ដាប់កន្លងមកបានត្រឹមត្រូវឬអត់។ល។
- អាកប្បកិរិយាជាគ្រូអាចារ្យ រើសអើង ត្រូវទុកមួយឡែកនៅពេលសន្ទនា ហើយត្រូវប្រកាន់ជាប់នូវអារម្មណ៍យល់ចិត្តដៃគូសន្ទនា ទោះជាមិនយល់ស្របតាមគំនិតដៃគូសន្ទនាក៏ដោយ។ល។

## ៤.៨- ភាពជាអ្នកដឹកនាំ

ពលរដ្ឋដែលមានសមត្ថភាពជាអ្នកដឹកនាំ តែងតែមានទំនាក់ទំនងសង្គមទៅជាមួយបុគ្គលិកការងារល្អ ចេះបញ្ចុះបញ្ចូលឲ្យបុគ្គលិកពេញចិត្ត ពោរពេញទៅដោយឆន្ទៈខ្ពស់ បំពេញការងារ សម្រេចបានគោលដៅដែលបានរំពឹងទុក។

ពលរដ្ឋដែលមានភាពជាអ្នកដឹកនាំត្រូវមានសមត្ថភាពដូចខាងក្រោមៈ

- ចេះរៀបចំឱ្យមានចក្ខុវិស័យច្បាស់លាស់

- ចេះធ្វើឱ្យបុគ្គលិកយល់ច្បាស់ អំពីចក្ខុវិស័យ គោលដៅរបស់ស្ថាប័នដែលខ្លួនធ្វើការ ស្គាល់ភារកិច្ច ព្រមទាំងតួនាទីរបស់ខ្លួនត្រូវបំពេញ
- ផ្តល់សេចក្តីទុកចិត្តដល់បុគ្គលិក ធ្វើឱ្យបុគ្គលិកមានភាពជឿជាក់លើខ្លួនឯង ក្លាហាន និងហ៊ានធ្វើសេចក្តីសម្រេចចិត្ត ដោះស្រាយបញ្ហាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់
- ការលើកទឹកចិត្តដល់បុគ្គលិក រួមទាំងកសាងសមត្ថភាពបុគ្គលិក នាំឱ្យបុគ្គលិកកាន់តែវៃឆ្លាត បំពេញការងារកាន់តែមានគុណភាពនិងប្រសិទ្ធភាពខ្ពស់
- ចេះការពារកូនចៅ នាំឱ្យកូនចៅមានភាពស្មោះស្ម័គ្រ ទាំងចំពោះថ្នាក់ដឹកនាំ និងកន្លែងធ្វើការ ឬក្រុមហ៊ុន
- មានទំនួលខុសត្រូវខ្ពស់
- ជាបុគ្គលគំរូ ទាំងផ្នែកចិត្តសុខភាពនិងកាយសុខភាព ព្រមទាំងមានសមត្ថភាពជាច្រើនទៀតដូចជា ប្រាស្រ័យទាក់ទង ធ្វើការងារជាក្រុម អត់ធ្មត់ ចេះចាត់ចែង ធ្វើប្រតិភូកម្ម និងច្នៃប្រឌិត។ល។

## ៤.៩ - សហគ្រិនភាព

ពលរដ្ឋដែលស្រឡាញ់មុខរបររកស៊ី ដោយសារគេស្រឡាញ់សេរីភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត តែមិនប្រាសចាកពីគោលការណ៍ច្បាប់សហគ្រិន។

គោលដៅចម្បងបុគ្គលសហគ្រិនភាព គឺពង្រឹងនិងពង្រីកសេដ្ឋកិច្ចគ្រួសារ និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

អ្នកមានសហគ្រិនភាព តែងតែធ្វើសេចក្តីសម្រេចចិត្តដោយមិនមានងាករេ មិនឱ្យឥទ្ធិពលពីខាងក្រោមកជ្រៀតជ្រែក ហ៊ានប្រឈមមុខទៅនឹងរាល់ហានិភ័យដែលអាចកើតឡើង។

សមត្ថភាពសហគ្រិនភាព ត្រូវមានបន្ថែមគឺ៖ ភាពជាអ្នកដឹកនាំ ចេះធ្វើការបត់បែនតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែង។

## ៥- ជំនាញរឹង និងជំនាញទន់

### ៥.១- និយមន័យជំនាញរឹង

- ជាចំណេះដឹងដែលពលរដ្ឋទទួលបានតាមរយៈការសិក្សា ការអប់រំ ការចូលរួមវគ្គបណ្តុះបណ្តាល ដែលមានរយៈពេលវែង ឬខ្លី និងស្វ័យសិក្សាពេញមួយជីវិត។ ជំនាញរឹងនេះពលរដ្ឋត្រូវការ សម្រាប់យកទៅអនុវត្តក្នុងពេលប្រកបមុខរបរផ្សេងៗ ដើម្បីរកប្រភពចំណូល លើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម
- ជាសមត្ថភាពដែលអាចធ្វើការវាស់វែងបានតាមរយៈការប្រឡងដាក់ពិន្ទុ។ ជំនាញរឹងជាចំណេះដឹងផ្នែកអក្សរសាស្ត្រ លេខសាស្ត្រ ភាសាបរទេស ព្រមទាំងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។

### ៥.២- និយមន័យជំនាញទន់

- ជាភាពប៉ិនប្រសប់ប្រើប្រាស់ជំនាញរឹង ប្រកបដោយប្រសិទ្ធភាព គុណភាព ទាំងក្នុងពេលសិក្សា និងក្នុងពេលប្រកបមុខរបរផ្សេងៗ។ បើយើងប្រើប្រាស់ជំនាញរឹងបានកាន់តែមានប្រសិទ្ធភាព និងគុណភាព មានការវិភាគត្រិះរិះ ពិចារណា ច្នៃប្រឌិត និងបង្កើតថ្មី នាំឱ្យការប្រឡងប្រជែងទីផ្សារការងាររបស់យើងបានកាន់តែល្អ និងទូលំទូលាយ
- ជំនាញទន់ក៏ជាឥរិយាបថរបស់ពលរដ្ឋម្នាក់ៗផងដែរ ដែលជាគុណប្រយោជន៍សម្រាប់គ្រប់គ្រងខ្លួនឯង និងរស់នៅក្នុងសង្គម ទាំងគ្រួសារតូច គ្រួសារធំ នៅសាលារៀន និងនៅកន្លែងប្រកបមុខរបរផ្សេងៗ ប្រកបដោយសុខដុមនីយកម្មជាមួយគ្នា។ ជំនាញទន់ ជាតម្រូវការសម្រាប់អភិវឌ្ឍបុគ្គល គ្រួសារ

និងសង្គម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ តាមរយៈចេះនិងស្រឡាញ់សិក្សាពេញមួយជីវិត មានចិត្តសុខភាព និងកាយសុខភាពល្អ មានភាពជាអ្នកដឹកនាំ និងសហគ្រិនភាព

- ជំនាញទន់ មិនអាចធ្វើការវាស់វែងបានដូចជំនាញរឹងទេ។

ជំនាញរឹងនិងជំនាញទន់ទាំងពីរនេះមានតួនាទីសំខាន់ដូចគ្នាសម្រាប់ពលរដ្ឋរស់នៅក្នុងសង្គមទីផ្សារសេរីនាសតវត្សទី២១ និងក្នុងប្រទេសដែលបានធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។

ជាការពិតណាស់ យើងមានការលំបាកក្នុងការវាស់ និងវាយតម្លៃជំនាញទន់ទៅលើបុគ្គលណាមួយបានភ្លាមៗ។ ដូចនេះហើយបានជា នៅពេលនិយោជកម្នាក់ ឬស្ថាប័នណាមួយមានបំណងជ្រើសរើសបុគ្គលិកទទួលខុសត្រូវកិច្ចការអ្វីមួយ ឯកសារសំខាន់ដែលនិយោជក ចាប់អារម្មណ៍មុនគេគឺ ប្រវត្តិរូបសង្ខេបរបស់អនាគតនិយោជិក។ ព័ត៌មាននៅក្នុងប្រវត្តិរូបសង្ខេប ដែលនិយោជកចង់ដឹងគឺទាំងជំនាញរឹង និងជំនាញទន់របស់អនាគតនិយោជិក។

ចង់ដឹងពីជំនាញរឹងរបស់អនាគតនិយោជិកមានការងាយទេ ព្រោះនិយោជកអាចដឹងតាមរយៈសញ្ញាប័ត្រ វិញ្ញាបនបត្រ ឬឯកសារពាក់ព័ន្ធផ្សេងទៀត ដែលភ្ជាប់មកជាមួយ។

ចង់ដឹងពីជំនាញទន់របស់អនាគតនិយោជិកទើបវាលំបាក។ បើអនាគតនិយោជិកធ្លាប់បានធ្វើការងារមួយដែលមានរយៈពេលយូរឆ្នាំ ចំទៅនឹងសមត្ថភាពវិជ្ជាជីវៈដែលខ្លួនមាន និយោជកអាចសន្និដ្ឋានបានជាដំបូងថា អនាគតនិយោជិក អាចមានជំនាញ ឬបទពិសោធន៍ក្នុងការប្រើប្រាស់សមត្ថភាពវិជ្ជាជីវៈ ឬមានបំណិនប្រើប្រាស់ចំណេះដឹងបានល្អ។ តែដើម្បីដឹងពីឥរិយាបថ របស់អនាគតនិយោជិក និយោជកត្រូវសិក្សាស្វែងយល់បន្ថែមទៅលើបុគ្គលិកលក្ខណសម្បត្តិអនាគតនិយោជិកនោះ។ តាមរយៈការធ្វើវិភាគ ត្រិះរិះ ពិចារណាលើកន្លែងដែលអនាគត

និយោជិកធ្លាប់បានធ្វើការកន្លងមក និយោជកអាចធ្វើការវាយតម្លៃពី ជំនាញទន់អនាគតនិយោជិកបានខ្លះ។

ឧទាហរណ៍បើនៅកន្លែងផ្តល់សេវាកម្ម កន្លែងការងារសង្គមកិច្ច អនាគតនិយោជិកអាចមានសមត្ថភាពសង្គមច្រើន ដូចជាប្រាស្រ័យទាក់ទង កាយសុខភាព ចិត្តសុខភាព ។ល។

បើនៅកន្លែងចង្វាក់ផលិតកម្ម ក្នុងរោងចក្រ អនាគតនិយោជិក អាចមានសមត្ថភាព ធ្វើការងារជាក្រុមល្អ។ល។

### ៥.៣- សមាសភាគជំនាញទន់

តាមរយៈការបកស្រាយពីជំនាញទន់ខាងលើ យើងអាចសន្និដ្ឋានបានថា សមាសភាគជំនាញទន់មានបីធំៗ គឺ៖

- វិធីសាស្ត្រ ឬសមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹង
- សមត្ថភាពបុគ្គល និង
- សមត្ថភាពសង្គម។

#### ៥.៣.១- សមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹង

សមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹង យើងអាចនិយាយបានថាជាវិធីសាស្ត្រក្នុងប្រើប្រាស់ចំណេះដឹង ជាជំនាញទន់ដែលតែងតែមានទំនាក់ទំនងទៅនឹងជំនាញរឹងជានិច្ច។ ឧទាហរណ៍៖ គ្រូឧទ្ទេសម្នាក់ប្រើកម្មវិធីកុំព្យូទ័រមួយឈ្មោះថា PowerPoint សម្រាប់ធ្វើបទបង្ហាញចែករំលែកចំណេះដឹងជាជំនាញរឹង។ ចំណែកឯវិធីសាស្ត្រក្នុងការប្រើកម្មវិធី PowerPoint នេះ រួមទាំងជ្រើសរើសយកប្រភេទតួអក្សរទំហំតួអក្សរពណ៌ និងការរៀបចំខ្លឹមសារធ្វើយ៉ាងណាឱ្យក្រុមទិសដៅងាយយល់ និងស្តាប់ព្រមទាំងចាំបាន នេះជាជំនាញទន់។

សមាសភាគនៃសមត្ថភាពប្រើប្រាស់ជំនាញរឹងមាន ការសង្កេត វិភាគ ត្រិះរិះពិចារណា ចាត់ចែង ច្នៃប្រឌិតនិងបង្កើតថ្មី ដោះស្រាយបញ្ហា និងសម្រេចចិត្ត។ល។

### ៥.៣.២- សមត្ថភាពបុគ្គល

សមត្ថភាពបុគ្គល ជាសមត្ថភាពសម្រាប់ជាគុណប្រយោជន៍ដល់បុគ្គលខ្លួនឯងប្រើប្រាស់ក្នុងការគ្រប់គ្រងខ្លួនឯង ទាំងនៅក្នុងជីវភាពរស់នៅ ឬស្ថានភាព និងហេតុការណ៍ណាមួយកើតឡើងនៅក្នុងគ្រួសារ ក្នុងសាលារៀន កន្លែងបំពេញការងារ ឬតាមទីសាធារណៈ។ល។

សមាសភាគសមត្ថភាពបុគ្គលសំខាន់ៗមាន៖ ស្រឡាញ់ការសិក្សា ចង់ដឹងចង់ស្គាល់អ្វីដែលថ្មី ការអត់ធ្មត់ ចេះគ្រប់គ្រងនិងមានវិន័យលើខ្លួនឯង មានភាពក្លាហាន និងជឿជាក់លើសមត្ថភាពខ្លួនឯង ឯករាជ្យម្ចាស់ការ ចេះធ្វើការឆ្លុះបញ្ចាំងខ្លួនឯងដើម្បីកែលំអនិងអភិវឌ្ឍខ្លួន មានស្មារតីទទួលខុសត្រូវលើខ្លួនឯង លើកទឹកចិត្តខ្លួនឯង។ល។

### ៥.៣.៣- សមត្ថភាពសង្គម

ជាសមត្ថភាពសម្រាប់ជាគុណប្រយោជន៍ដល់បុគ្គលម្នាក់ៗ ធ្វើអន្តរកម្មជាមួយអ្នកដទៃ ម្នាក់ឬច្រើននាក់ ទាំងនៅក្នុងសង្គមគ្រួសារ នៅក្នុងសាលារៀន កន្លែងធ្វើការ និងនៅតាមទីសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសុខដុមរមនាជាមួយគ្នា។

សមាសភាគសមត្ថភាពសង្គមសំខាន់ៗមាន៖ ប្រាស្រ័យទាក់ទង សហការធ្វើការងារជាក្រុម កាយសុខភាព និងចិត្តសុខភាព មានឆន្ទៈទទួលការទិតៀនពីអ្នកដទៃ។ល។

***កំណត់សំគាល់:*** មិនដូចក្នុងវិស័យវិទ្យាសាស្ត្រពិតទេ វិស័យសិក្សាសង្គមយើងមិនអាចអះអាងថា សមត្ថភាពមួយដាច់ខាតជាសមត្ថភាពបុគ្គល ឬជាសមត្ថភាព

សង្គមបានទេ សមត្ថភាពទាំងអស់តែងតែមានទំនាក់ទំនង និងត្រូវការគ្នាទៅវិញទៅមក។ ឧទាហរណ៍ៈ ប្រាស្រ័យទាក់ទងជាសមត្ថភាពសង្គម តែដៃគូសន្ទនាត្រូវការសមត្ថភាពបុគ្គលជាច្រើន ដូចជាអត់ធ្មត់ គ្រប់គ្រងនិងមានវិន័យខ្លួនឯង ក្លាហាន និងជឿជាក់លើសមត្ថភាពខ្លួនឯង។ល។

តាមរយៈការបកស្រាយខាងលើនេះ យើងអាចសន្និដ្ឋានបានថា ជំនាញរឹងជាវិជ្ជាសម្បទា ចំណែកឯជំនាញទន់ជាសមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹង ឬបំណិនសម្បទា រីឯសមត្ថភាពបុគ្គល និងសមត្ថភាពសង្គមជាចរិយាសម្បទា។

## តារាងទី១ សមត្ថភាពសតវត្សទី២១ពលរដ្ឋសិក្សាពេញមួយជីវិត

| សមត្ថភាពសតវត្សទី២១ ពលរដ្ឋសិក្សាពេញមួយជីវិត | | | |
|---|---|---|---|
| ជំនាញរឹង | ជំនាញទន់ | | |
| | សមត្ថភាពប្រើប្រាស់ជំនាញរឹង | សមត្ថភាពបុគ្គល | សមត្ថភាពសង្គម |
| - អក្សរសាស្ត្រ<br>- លេខសាស្ត្រ<br>- ភាសាបរទេស និង<br>- បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ | - បំណិនសង្កេត<br>- បំណិនវិភាគ ត្រិះរិះ ពិចារណា<br>- បំណិនសម្រេចចិត្ត<br>- បំណិនច្នៃប្រឌិត និងបង្កើតថ្មី<br>- បំណិនចាត់ចែង<br>- បំណិនដោះស្រាយបញ្ហា។ល។ | - ការសិក្សាពេញមួយជីវិត<br>- អត់ធ្មត់ តស៊ូព្យាយាម<br>- ក្លាហាននិងជឿជាក់លើសមត្ថភាពខ្លួនឯង<br>- មានវិន័យលើខ្លួនឯង<br>- លើកទឹកចិត្តខ្លួនឯង<br>- ចេះឆ្លុះបញ្ចាំងខ្លួនឯង<br>- ស្មារតីទទួលខុសត្រូវ។ល។ | - ចិត្តសុខភាព<br>- កាយសុខភាព<br>- លះបង់និងចែករំលែក<br>- ទទួលការទិតៀនពីអ្នកដទៃ<br>- ការងារជាក្រុម<br>- ប្រាស្រ័យទាក់ទង<br>- ភាពជាអ្នកដឹកនាំ<br>- សហគ្រិនភាព។ល។ |

## ៦- គុណប្រយោជន៍ជំនាញទន់សម្រាប់កុមាររៀននៅសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា

នៅក្នុងជំពូកទាំង៥ខាងលើ មានការបកស្រាយច្បាស់ណាស់ថា ដើម្បីភាពជោគជ័យ ទាំងក្នុងជីវិតសិក្សា ជីវភាពរស់នៅជាប្រចាំ ទាំងជីវិតឯកជន ការរស់នៅក្នុងសង្គម នៅកន្លែងធ្វើការ ពលរដ្ឋគ្រប់រូបចាំបាច់ត្រូវមាន ទាំងជំនាញរឹង និងជំនាញទន់។

នៅក្នុងជំពូកទី៦នេះ យើងនឹងស្វែងយល់ទាំងអស់គ្នាថា តើសមត្ថភាពជំនាញទន់ណាខ្លះ កុមារត្រូវមាននិងទទួលបានតាមរយៈការអប់រំនៅសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា។

ជាការពិតណាស់ យើងក៏បានដឹងទាំងអស់គ្នាដែរថា  មានជំនាញទន់ចាំបាច់ជាច្រើន កុមារទទួលបានតាមរយៈការអប់រំពីឪពុកម្តាយនៅតាមគេហដ្ឋាន និងតាមរយៈឥទ្ធិពលសង្គមជុំវិញកន្លែងដែលកុមាររស់នៅ។ ជំនាញទន់នេះយើងឱ្យនិយមន័យថា ជាសមត្ថភាពកុមារមានស្រាប់។

ការអប់រំជំនាញទន់ដល់កុមារប្រកបដោយវិជ្ជាជីវៈ គឺចាប់ផ្តើមនៅសាលាមត្តេយ្យ និងតាមភូមិសិក្សាជាបន្តបន្ទាប់ ធ្វើឡើងទៅតាមបទដ្ឋានគរុកោសល្យ និងទិសដៅច្បាស់លាស់។

ជាការពិតណាស់ រាល់ឪពុកម្តាយ ដែលជាអាណាព្យាបាលកុមារ តែងតែមានបំណងចង់ឃើញកូនរបស់គាត់ ចេះរស់នៅក្នុងសង្គមប្រកបដោយសុខដុមនីយកម្ម និងទទួលបានជោគជ័យជាបន្តបន្ទាប់ ទាំងជីវិតក្នុងការសិក្សា និងប្រកបមុខរបរចិញ្ចឹមជីវិត។

ដើម្បីសម្រេចបាននូវបំណងខាងលើនេះ ឪពុកម្ដាយដែលជាអ្នកអាណាព្យាបាលកុមារតែងតែមានការលះបង់ខ្ពស់ ធ្វើយ៉ាងណាឱ្យកូនរបស់គាត់ ត្រៀមខ្លួនបានល្អ ចូលរៀននៅសាលាមត្តេយ្យ ឬសាលាបឋមសិក្សា។

ឪពុកម្ដាយកុមារតែងតែ ព្យាយាមសហការ ជាមួយគ្រូសាលាមត្តេយ្យ ឬគ្រូបឋមសិក្សា នៅពេល៖

- កុមារចូលរៀនសាលាមត្តេយ្យ ឬ
- កុមារត្រៀមខ្លួនកុមារចូលរៀនថ្នាក់ទី១សាលាបឋមសិក្សាដើមឆ្នាំសិក្សា។

នៅពេលកុមារដល់ ឬគ្រប់អាយុចូលរៀននៅសាលាមត្តេយ្យ ឬថ្នាក់ទី១សាលាបឋមសិក្សា តិចឬច្រើន កុមារគួរមានសមត្ថភាពមួយចំនួន ដែលហៅថាសមត្ថភាពកុមារមានស្រាប់ ឧទាហរណ៍ដូចជា៖

- **ភាពក្លាហាន និងជឿជាក់លើខ្លួនឯង** សម្រាប់ជាគុណប្រយោជន៍ ដើម្បីឱ្យកុមារងាយទទួលយកបានក្នុងការរស់នៅក្នុងបរិស្ថាន បរិបទ និងលក្ខខណ្ឌសិក្សារៀនសូត្រថ្មី រាប់អានមិត្តថ្មី សហការ លេង រៀនជាមួយកុមារដទៃដែលមិនធ្លាប់ស្គាល់ពីមុន។ល។
- **ភាពឯករាជ្យម្ចាស់ការ** សម្រាប់ជាគុណប្រយោជន៍ កុមារអាចធ្វើកិច្ចការដោយខ្លួនឯងជាបន្តបន្ទាប់ មិនមានអ្នកជួយ បើមិនចាំបាច់។ល។
- **គ្រប់គ្រងអារម្មណ៍ខ្លួនឯង** សម្រាប់ជាគុណប្រយោជន៍ ក្នុងការរស់នៅគោរពវិន័យ និងបទបញ្ជារបស់សាលា ដែលជាទម្លាប់ កុមារត្រូវមាន និងអនុវត្តពេញមួយជីវិត។
- **សមត្ថភាពសហការ** ជាគុណប្រយោជន៍ សម្រាប់កុមារ ទាំងពេលលេង ពេលរៀន និងធ្វើកិច្ចការសាលាជាមួយកុមារផ្សេងទៀតមិនមានជម្លោះ និងចេះដោះស្រាយបញ្ហា ប្រកបដោយភាពអត់ធ្មត់

- **ការប្រាស្រ័យទាក់ទង** គឺជាការទម្លាប់និយាយទៅកាន់អ្នកដទៃ រួមទាំងគ្រូ និងមិត្តរួមថ្នាក់ ប្រកបដោយក្រមសីលធម៌ ភាពស្មោះត្រង់ គោរពនិងឱ្យតម្លៃ អ្នកដទៃ
- **ស្មារតីទទួលខុសត្រូវ** ជាទម្លាប់ត្រូវមានក្នុងការបំពេញភារកិច្ចពោរពេញទៅដោយការតស៊ូ និងអត់ធ្មត់
- **ទទួលការទិតៀនពីអ្នកដទៃ** សម្រាប់ជាគុណប្រយោជន៍ កែលម្អ អភិវឌ្ឍខ្លួនជាបន្តបន្ទាប់។

ខាងក្រោមនេះជាការបកស្រាយសង្ខេបស្តីពីជំនាញទន់សំខាន់ៗមួយចំនួន ដែលកុមារទទួលបានតាមរយៈការអប់រំ ព្រមទាំងពង្រឹងបន្ថែមនៅសាលាមត្តេយ្យ និងបឋមសិក្សា។

## ៦.១- កុមារមានចិត្តចង់ចេះ ចង់ដឹង និងស្រឡាញ់ការសិក្សា

កុមារមានមហិច្ឆតាចង់ចេះ ចង់ដឹង និងពេញចិត្តលើខ្លឹមសារមេរៀនដែលបង្រៀន ធ្វើរាល់កិច្ចការដែលគ្រូដាក់ឱ្យធ្វើនៅសាលាមត្តេយ្យសិក្សានិងសាលាបឋមសិក្សាកាន់តែខ្លាំង ពេលណា៖

- កុមារមានចំណាប់អារម្មណ៍ លើខ្លឹមសារមេរៀននោះនិង
- មានការគិតគូរពីសមត្ថភាពកុមារមានស្រាប់ ។

ការមិនធ្វើអ្វីគ្រប់យ៉ាងឱ្យកុមារចេះត្រឹមតែធ្វើតាម ជាមធ្យោបាយនាំឱ្យកុមារមានទម្លាប់ ធ្វើកិច្ចការដោយប្រើគំនិតខ្លួនឯង។

មានវិធីសាស្ត្រជាច្រើន យើងអាចអប់រំកុមារ មានចិត្តចង់ចេះចង់ដឹង ពេញចិត្តក្នុងការរៀនសូត្រដូចជា៖

- លើកស្ទួយកម្លាំងចិត្តរៀនសូត្រដល់កុមារ តាមរយៈការសរសើរកុមារ ផ្តល់រង្វាន់ដល់កុមារ កុមារទទួលបានពិន្ទុល្អ ពេលកុមារធ្វើអ្វីមួយបានល្អ

- មិនត្រូវស្តីបន្ទោសកុមារ ពេលកុមារធ្វើអ្វីមួយមិនបានល្អ តែណែនាំកុមារឱ្យខិតខំបន្តការរៀនសូត្រ និងប្រឹងប្រែងបន្ថែមទៀត
- ការផ្តល់ឱកាសឱ្យកុមារបានច្រើនក្នុងការចូលរួម ទាំងលើការគិតគូនិងចូលរួមធ្វើ។ តាមរយៈការសិក្សាបែបធ្វើនិងអនុវត្តគម្រោង កុមារមានឱកាសចូលរួមទាំងធ្វើផែនការ និងការអនុវត្តរហូតដល់វាយតម្លៃការអនុវត្តគម្រោង
- មានចម្លើយលើរាល់សំណួររបស់កុមារ ទោះជាកុមារត្រូវរង់ចាំបន្តិចក៏ដោយ
- ផ្តល់ឱកាសឱ្យកុមារប្រើប្រាស់សមត្ថភាពដែលកុមារមានស្រាប់ តាមរយៈផ្តល់តួនាទីដល់កុមារ ដូចជាណែនាំកុមារឱ្យជួយពន្យល់ ឬបង្រៀនដល់កុមារដែលខ្សោយជាងខ្លួន។ល។

មួយវិញទៀត ដើម្បីលើកទឹកចិត្តកុមារឱ្យស្រឡាញ់ការសិក្សា និងពេញចិត្តទៅសាលារៀន លុះត្រាតែតម្រូវការចាំបាច់ជាច្រើនរបស់កុមារត្រូវបានបំពេញដូចជាមានបន្ទប់អនាម័យគ្រប់គ្រាន់ បរិយាកាសសិក្សាទាំងក្នុងនិងក្រៅថ្នាក់ល្អ ដោយមានការរៀបចំតាមរយៈការចូលរួមពីកុមារផងដែរ។ មានអាហារសម្រន់ឆ្ងាញ់ពោរពេញជីវជាតិគ្រប់គ្រាន់ (បើមាន) មានកន្លែងកុមារសម្រាកថ្ងៃត្រង់ (បើកុមារនៅសាលាពេញមួយថ្ងៃ) មានសួនកុមារប្រកបដោយភាពទាក់ទាញ មានទីធ្លាធំទូលាយ។ល។

កុមារដែលស្រឡាញ់ការសិក្សា មានមហិច្ឆតាចង់ចេះចង់ដឹង កុមារ៖
- មានឱកាសក្នុងការបណ្តុះគំនិតច្នៃប្រឌិត បង្កើតថ្មី និងហ៊ានមានការស្រមើស្រមៃច្រើន
- មានឱកាសអភិវឌ្ឍខ្លួន និងទទួលបានជោគជ័យក្នុងជីវិតសិក្សា និងការងារប្រកបមុខរបរផ្សេងៗពេញមួយជីវិត។ល។

សរុបសេចក្តី កុមារមានចិត្តចង់ចេះ ចង់ដឹង និងស្រឡាញ់ការសិក្សា ពេលណាកុមារមានចំណាប់អារម្មណ៍លើខ្លឹមសារមេរៀន និងតម្រូវការ ព្រមទាំងសមត្ថភាពកុមារមានស្រាប់ ត្រូវបានគិតគូរ។

## ៦.២- កុមារមានចិត្តអត់ធ្មត់

សមត្ថភាពនេះ មិនមែនជាសមត្ថភាពកើតមានឡើងពីធម្មជាតិលើមនុស្សគ្រប់រូបនោះទេ តែជាសមត្ថភាពដ៏សំខាន់មួយសម្រាប់ជីវិតមនុស្សគ្រប់វ័យត្រូវមាន។

សមត្ថភាពអត់ធ្មត់នេះ កុមារគ្រប់រូបត្រូវតែទទួលបានពង្រឹង និងអប់រំជាបន្តបន្ទាប់ឱ្យខានតែបាន។

កុមារត្រូវរៀននិងទម្លាប់ពង្រឹងសមត្ថភាពអត់ធ្មត់នេះ ទុកជាគុណប្រយោជន៍ទាំងក្នុងជីវិតឯកជនផង ការរស់នៅក្នុងសង្គម និងធ្វើការងារជាក្រុមផង។ល។

សង្គមមួយមានភាពអនាធិបតេយ្យ ពិបាកក្នុងការគ្រប់គ្រង នៅពេលណាពលរដ្ឋនៅក្នុងសង្គមនោះ មានភាពទន់ខ្សោយលើសមត្ថភាព អត់ធ្មត់នេះ។

ជាការពិតណាស់ អប់រំកុមារមានសមត្ថភាពជំនាញទន់ «**អត់ធ្មត់**» មិនមែនធ្វើថ្ងៃនេះ ថ្ងៃស្អែកនឹងទទួលបានលទ្ធផលនោះទេ តែត្រូវចាប់ផ្តើមតាំងពីកុមារនៅតូច។

ការអប់រំកុមាររៀនចេះអត់ធ្មត់ ទទួលបានលទ្ធផលល្អ លុះត្រាយើងទាំងអស់គ្នាជាអ្នកអប់រំៈ

- ត្រូវរក្សាពាក្យសន្យា ពាក្យសម្តី ជាមួយកុមារឱ្យបាន
- ធ្វើជាគំរូដល់កុមារលើសមត្ថភាព អត់ធ្មត់នេះ
- ណែនាំកុមារធ្វើកិច្ចការដែលត្រូវការសមត្ថភាព អត់ធ្មត់នេះឱ្យបានច្រើន ជាពិសេសណែនាំឱ្យកុមារចេះរង់ចាំវេន
- ទម្លាប់កុមារគោរពលក្ខខណ្ឌច្បាស់លាស់ ឧទាហរណ៍ៈ កុមារអាចញ៉ាំអាហារសម្រន់បាន លុះត្រាកុមារលាងដៃនឹងសាប៊ូរួចជាមុន ឬលេងជាមួយមិត្តភក្តិបន្តបាន លុះត្រាកុមារអង្គុយស្ងាត់ស្ងៀម កុំឡូឡា។ល។

- ធ្វើការសរសើរដល់កុមារជានិច្ច ពេលណាកុមារបានបង្ហាញពីសមត្ថភាព ជំនាញទន់ «អត់ធ្មត់» នេះ។ល។

អប់រំកុមារឱ្យមានសមត្ថភាព អត់ធ្មត់ ជាគុណប្រយោជន៍

- ផ្តល់ឱកាសដល់កុមារក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រង និងមានវិន័យលើខ្លួនឯងសម្រាប់ភាពជោគជ័យក្នុងជីវិតសិក្សា និងការងារប្រកបមុខរបរផ្សេងៗពេញមួយជីវិត។

**អប់រំកុមារឱ្យមានសមត្ថភាព ជំនាញទន់ «អត់ធ្មត់»**
**ត្រូវការពេលវេលាដោយត្រូវចាប់ផ្តើមតាំងពីកុមារនៅតូច និងជាបន្តបន្ទាប់ពេញមួយជីវិត។**

## ៦.៣- កុមារមានវិន័យលើខ្លួនឯង

មានវិន័យលើខ្លួនឯង សម្រាប់កុមារមានន័យថា៖ កុមារអាចគ្រប់គ្រងខ្លួនឯងបានទាំងក្នុងជីវិតសិក្សា ជីវិតឯកជន និងការរស់នៅក្នុងសង្គម។

អប់រំកុមារ ឱ្យមានវិន័យ និងគ្រប់គ្រងខ្លួនឯង៖

- គ្រូធ្វើជាគំរូដល់កុមារលើការគ្រប់គ្រងនិងមានវិន័យលើខ្លួនឯង
- គ្រូណែនាំកុមារ ទម្លាប់អនុវត្តកិច្ចការ តាមកាលបរិច្ឆេទ និងផែនការ
- មានវិធានការពេលណាកុមារមិនធ្វើតាមការណែនាំ ដោយពន្យល់ពីហេតុផលនៅពីក្រោយវិធានផ្សេងៗនេះ
- សរសើរ និងលើទឹកចិត្តដល់កុមារដែលមានសមត្ថភាពនេះ
- អប់រំកុមារឱ្យចេះដោះស្រាយបញ្ហាដោយខ្លួនឯង ដែលពាក់ព័ន្ធទៅនឹងការពង្រឹងសមត្ថភាពមានវិន័យលើខ្លួនឯង។ល។

កុមារដែលមានវិន័យលើខ្លួនឯងជា ៖

- កុមារដែលអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបានល្អ មិនងាយឱ្យសភាពការណ៍ណាមួយទាក់ទាញ ឬរំខានគាត់បានទេ ពេលកុមារកំពុងធ្វើកិច្ចការអ្វីមួយ
- កុមារតែងតែមានប្រតិកម្មដោយប្រុងប្រយ័ត្នបំផុត ទៅលើរាល់ហេតុការណ៍អ្វីមួយដែលកើតឡើង
- កុមារមានការប្តេជ្ញាចិត្តខ្ពស់ នៅពេលកុមារធ្វើ ឬសហការកិច្ចការអ្វីមួយ
- កុមារមានឆន្ទៈខ្ពស់ មិនងាយបោះបង់ការងារដោយងាយៗ។ល។

ឧទាហរណ៍៖ កុមារមានវិន័យលើខ្លួនឯង យើងអាចសន្និដ្ឋានបានថា កុមារតែងតែមានអាកប្បកិរិយាដូចខាងក្រោម៖

- សម្រាប់កុមារអាយុ៤ឆ្នាំ ពេលកុមារចង់បានវត្ថុមួយជារបស់ខ្លួនពីមិត្តភក្តិមកវិញ តែមិត្តភក្តិមិនព្រមឱ្យ កុមារមិនប្រើអំពើហិង្សាទៅលើមិត្តភក្តិខ្លួនទេ តែកុមារព្យាយាមនិយាយជាមួយមិត្តភក្តិខ្លួន ឬហៅម្តាយ ឪពុក ឬគ្រូឱ្យជួយយកវត្ថុនោះឱ្យកុមារវិញ
- សម្រាប់កុមារអាយុ៧ឆ្នាំ កុមារធ្វើកិច្ចការសាលាជាមុន មុនពេលកុមារទៅចូលរួមលេងជាមួយមិត្តភក្តិរបស់ខ្លួន
- សម្រាប់កុមារអាយុ៨ឆ្នាំ កុមារចេះនិងហ៊ានបដិសេធមិនចូលរួមជាមួយមិត្តភក្តិណា ដែលកំពុងតែរករឿងកុមារផ្សេងទៀត
- សម្រាប់កុមារអាយុ១២ឆ្នាំ កុមារចេះសន្សំលុយ រាល់ថ្ងៃ រហូតដល់កុមារអាចទិញរបស់ដែលកុមារចង់បានដោយខ្លួនឯង។ល។

**អប់រំកុមារឱ្យមានវិន័យលើខ្លួនឯង**

**ជាភារកិច្ចទាំងអស់គ្នា ទាំងឪពុកម្តាយដែលជាអាណាព្យាបាលកុមារ គ្រូកុមារមត្តេយ្យ និងគ្រូបង្រៀននៅតាមភូមិសិក្សាជាបន្តបន្ទាប់។**

## ៦.៤- កុមារជឿជាក់លើសមត្ថភាពខ្លួនឯង

កុមារដែលមានសមត្ថភាព ជឿជាក់លើសមត្ថភាពខ្លួនឯង តែងតែមានគោលជំហរវិជ្ជមាន រឹងមាំ មានភាពក្លាហាន ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត មានភាពឯករាជ្យម្ចាស់ការ និងស្មារតីទទួលខុសត្រូវខ្ពស់។ ទស្សនៈសុទិដ្ឋិនិយម ក៏កើតឡើងពីសមត្ថភាពជឿជាក់លើសមត្ថភាពខ្លួនឯងនេះដែរ។

ពង្រឹងនិងអប់រំសមត្ថភាពនេះដល់កុមារ ដោយធ្វើយ៉ាងណា៖

- ធានាផ្ដល់ឱកាសដល់កុមារ មានបទពិសោធន៍វិជ្ជមានឱ្យបានច្រើន។ កិច្ចការដែលកុមារត្រូវបំពេញ មិនត្រូវស្រួល និងងាយ ឬលំបាកពេក រហូតដល់កុមារមិនអាចធ្វើបាននោះទេ
- មិនសើចចំអកកុមារ ឬស្ដីបន្ទោសកុមារ ពេលកុមារធ្វើអ្វីមួយមិនទាន់បានសម្រេច។ ការសើចចំអកនាំឱ្យកុមារបាត់បង់ភាពក្លាហានរហូតដល់ការបាត់បង់ភាពជឿជាក់លើសមត្ថភាពខ្លួនឯង
- លើកទឹកចិត្តកុមារប្រើប្រាស់សមត្ថភាពដែលកុមារមានស្រាប់ មកធ្វើជាគុណប្រយោជន៍សម្រាប់អប់រំកុមារលើសមត្ថភាព ជឿជាក់លើសមត្ថភាពខ្លួនឯង
- ជៀសវាងរាល់ទង្វើ ឬសម្ដីណា ដែលនាំឱ្យប៉ះពាល់លើអារម្មណ៍របស់កុមារ។ គ្រូមិនត្រូវប្រើពាក្យ «គ្រូឈប់ស្រឡាញ់ ឈប់ជឿកូនហើយ»។ល។
- នាំកុមារហាត់និងលេងកីឡារហូតដល់កុមារមានការជឿជាក់លើសមត្ថភាពខ្លួនឯង
- មិនត្រូវប្រៀបធៀបកុមារ ណាខ្លាំង ណាខ្សោយ ជាពិសេសទៅលើសាមីខ្លួនដែលកំពុងមានវត្តមានជាមួយគ្នា
- ផ្ដល់ឱកាសដល់កុមារឱ្យបានច្រើនអាចធ្វើកិច្ចការ និងដោះស្រាយបញ្ហាដោយខ្លួនឯង

- ផ្ដល់ឱកាសដល់កុមារឱ្យបានច្រើនអាចធ្វើការសាកល្បងដោយខ្លួនឯង ទោះជាមានរយៈយូរបន្តិច ឬមិនបានជោគជ័យភ្លាមៗក៏ដោយ។ ការអនុវត្តជាក់ស្ដែងជាច្រើនដង នាំឱ្យកុមារកាន់តែមានភាពស្ទាត់ជំនាញ ជឿជាក់លើសមត្ថភាពខ្លួនឯង
- ពេលកុមារកំពុងធ្វើអ្វីមួយ យើងត្រូវធ្វើយ៉ាងណាឱ្យកុមារយល់ថា មានអ្នកនៅពីក្រោយខ្នងចាំជួយ ពេលកុមារមានបញ្ហា
- យកចិត្តទុកដាក់ និងឱ្យតម្លៃទស្សនៈរបស់កុមារ
- បង្កើតបរិយាកាសរៀនសូត្រសម្រាប់កុមារឱ្យបានល្អ ធ្វើយ៉ាងណាឱ្យកុមារមានអារម្មណ៍ថា កុមារកំពុងត្រូវបានទទួលការយកចិត្តទុកដាក់
- ត្រូវគិតថាកំហុសរបស់កុមារ ជាឱកាសសម្រាប់កុមាររៀនសូត្រ បន្តអភិវឌ្ឍខ្លួន ដោយមានការពន្យល់ដល់កុមារកុំឱ្យកុមារមានការភ័យខ្លាច និងមិនត្រូវយកកំហុសរបស់កុមារធ្វើជាគំនាប
- ផ្ដល់មតិត្រឡប់ដល់កុមារប្រកបដោយភាពស្ថាបនា និងស្មោះត្រង់ តែកុំធ្វើឡើងចំពោះមុខកុមារដទៃ
- គាំទ្ររាល់ការទិតៀនរបស់កុមារ ដែលមានលក្ខណៈស្ថាបនា
- យកចិត្តទុកដាក់ និងឆ្លើយរាល់សំណួររបស់កុមារ។ល។

**អប់រំ និងពង្រឹងសមត្ថភាព ជឿជាក់លើសមត្ថភាពខ្លួនឯងដល់កុមារ ធ្វើទៅបានជោគជ័យ លុះត្រាតែយើងដែលជាអ្នកអប់រំមាន និងយល់ពីអត្ថប្រយោជន៍នៃសមត្ថភាពនេះដែរ។**

## ៦.៥- កុមារចេះធ្វើការឆ្លុះបញ្ចាំងខ្លួនឯង

ការចេះធ្វើការឆ្លុះបញ្ចាំងខ្លួនឯង ជាបច្ច័យនាំឱ្យកុមារមានការផ្លាស់ប្តូរ និងអភិវឌ្ឍខ្លួនឈានទៅរកផ្លូវវិជ្ជមាន នាំឱ្យកុមារដឹងច្បាស់ថា អ្វីខ្លះជាតម្រូវការរបស់ខ្លួន អ្វីជាចំណុចខ្លាំង និងចំណុចខ្សោយដែលខ្លួនមាន។

ជាទូទៅ ឆ្លុះបញ្ចាំងខ្លួនឯងគឺជាសមត្ថភាពសម្រាប់ជាគុណប្រយោជន៍កុមារចេះធ្វើការវិភាគ ត្រិះរិះ ពិចារណា គិតគូឡើងវិញ លើរាល់សកម្មភាពដែលខ្លួនបានប្រព្រឹត្តកន្លងមក និងក្នុងបំណងកុមារអាចធ្វើការផ្លាស់ប្តូរ និងវិវឌ្ឍខ្លួន។

ការសិក្សារៀនសូត្រយល់ដឹងពីខ្លួនឯង កុមារត្រូវការពេលវេលា បរិយាកាសមួយមានភាពស្ងប់ស្ងាត់ និងអនុគ្រោះ។ យើងជាគ្រូអាចជួយដល់កុមារ ធ្វើការឆ្លុះបញ្ចាំងខ្លួនឯងបានតាមរយៈការផ្តល់យោបល់ ឬមតិត្រឡប់ ដោយគោរពគោលការណ៍ស្មោះត្រង់ និងស្តាបនា។

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួន ស្តីពីការងារអប់រំនិងពង្រឹងសមត្ថភាពកុមារ ចេះឆ្លុះបញ្ចាំងខ្លួនឯង៖

- ដឹកនាំកុមារធ្វើការឆ្លុះបញ្ចាំងទាំងអស់គ្នា លើសកម្មភាពដែលកុមារបានធ្វើកន្លងមួយថ្ងៃ មួយសប្តាហ៍ មួយខែ ដោយមិនមានដាក់បន្ទុក ឬកំហុសលើកុមារណាមួយ
- ផ្តល់ឱកាសដល់កុមារក្នុងការសម្រេចចិត្តដោយខ្លួនឯង ឧទាហរណ៍ៈ ជ្រើសរើសរឿងនិទានកុមារចង់ឱ្យគ្រូអានឱ្យស្តាប់ ដោយគ្រូសួរទៅកាន់កុមារថា ហេតុអ្វីបានជាកូនរើសយករឿងនិទាន «ក» មិនយករឿងនិទាន «ខ» ឱ្យគ្រូអានឱ្យស្តាប់?
- ណែនាំកុមារឱ្យឆ្លុះបញ្ចាំងស្តីពីអារម្មណ៍របស់កុមារម្នាក់ៗដែលកើតមានឡើង ឧទាហរណ៍ៈ កុមារម្នាក់យំ ដោយសារតែកុមារផ្សេងទៀតយករបស់

លេងរបស់ខ្លួន។ ក្រោមវត្តមានគ្រូជាអ្នកសម្របសម្រួល កុមារទាំងពីរនាក់នៅទល់មុខគ្នា ហើយធ្វើការឆ្លុះបញ្ចាំងពីសកម្មភាពដែលខ្លួនបានធ្វើ

- បើកុមារចង់ធ្វើអ្វីមួយដោយមានការបកស្រាយពីមូលហេតុដែលខ្លួនចង់ធ្វើបានត្រឹមត្រូវ ហើយបើគ្រូយល់ឃើញថា កុមារអាចធ្វើបាន គ្រូគួរអនុញ្ញាតឱ្យកុមារធ្វើ។

**គោលដៅអប់រំកុមារចេះធ្វើការឆ្លុះបញ្ចាំងខ្លួនឯង គឺពង្រឹងសមត្ថភាពកុមារឱ្យចេះគិត វិភាគ ត្រិះរិះ ពិចារណា និងរៀនសូត្រពីសកម្មភាពដែលខ្លួនបានធ្វើកន្លងមក ស្គាល់អ្វីជាចំណុចខ្លាំង និងខ្សោយរបស់ខ្លួន ដើម្បីងាយក្នុងការអភិវឌ្ឍនិងគ្រប់គ្រងខ្លួនឯងបានជាបន្តបន្ទាប់។**

## ៦.៦- កុមារចេះធ្វើកិច្ចការដោយខ្លួនឯង

អប់រំកុមារចេះធ្វើកិច្ចការដោយខ្លួនឯង មិនមែនមានន័យថា ទុកឱ្យកុមារធ្វើអ្វីតែឯង មិនមានអ្នកមើលការខុសត្រូវ ឬមិនមានអ្នកនៅក្បែរនោះទេ។ កិច្ចការឱ្យកុមារធ្វើដោយខ្លួនឯងបាន អាស្រ័យតាមអាយុនិងវ័យ ឬកម្រិតនៃការអភិវឌ្ឍរបស់កុមារ។

លក្ខខណ្ឌការអប់រំកុមារឱ្យចេះធ្វើកិច្ចការដោយខ្លួនឯង កុមារត្រូវនៅកន្លែងមួយដែលកុមារមានភាពកក់ក្ដៅ មិនមានអ្វីប៉ះពាល់ដល់អារម្មណ៍កុមារ ហើយកុមារដឹងច្បាស់ថា បើកុមារធ្វើអ្វីខុសនឹងមិនមានទោសពៃរ៍អ្វីកើតឡើងដល់កុមារឡើយ។

ខាងក្រោមនេះជាគន្លឹះមួយចំនួនក្នុងការអប់រំកុមារឱ្យចេះធ្វើកិច្ចការដោយខ្លួនឯងបានជាបន្តបន្ទាប់៖

- ផ្តល់ឱកាស រួមទាំងពេលវេលា និងទីកន្លែងដល់កុមារសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ សាកល្បងសមត្ថភាពភាព និងគំនិតដែលកុមារមានដោយខ្លួនឯង។ គ្រូមិនប្រាប់កុមារអ្វីៗទាំងអស់ដល់កុមារត្រូវធ្វើនោះទេ ទុកឱ្យកុមារព្យាយាមធ្វើការសិក្សាស្រាវជ្រាវ ឬដោះស្រាយបញ្ហាដោយខ្លួនឯង។ កុមារ

មានឱកាសធ្វើអ្វីៗដោយខ្លួនឯងបានកាន់តែច្រើន ឬច្រើនដង សមត្ថភាពកុមារចេះធ្វើកិច្ចការដោយខ្លួនឯងកាន់តែត្រូវបានពង្រឹង

- ផ្តល់ក្តីទុកចិត្តដល់កុមារកាន់តែច្រើន កុមារកាន់តែមានឱកាសច្រើនក្នុងការវាស់សមត្ថភាពរបស់ខ្លួន។ ពិតណាស់ រាល់ពេលកុមារកំពុងធ្វើសកម្មភាពអ្វីមួយ កុមារត្រូវមានអារម្មណ៍ថាមានសុវត្ថិភាព មានអ្នកនៅក្បែរចាំជួយបើមានហេតុការណ៍អ្វីកើតឡើង។ កុមារមិនទទួលបានការស្តីបន្ទោស បើកុមារធ្វើទៅមិនបាន ឬមិនបានល្អ។ រាល់ការអប់រំទ្រឹស្តីត្រូវផ្សារភ្ជាប់ជានិច្ចនឹងការអនុវត្តជាក់ស្តែង ឧទាហរណ៍ៈ អប់រំកុមារនៅសាលាមត្តេយ្យឱ្យចេះចិតសំបកផ្លែឈើដោយខ្លួនឯង កុមារត្រូវដឹងពីរបៀបកាន់កាំបិតប្រកបដោយសុវត្ថិភាព និងយល់ពីរបៀបចិតសំបកផ្លែឈើ ឬចិតបន្លែជាមុន
- ផ្តល់ឱកាសដល់កុមារធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងបានច្រើនដូចជាដាក់ប្រភេទនៃល្បែងលេងដល់កុមារ ឱ្យកុមាររើសយកល្បែងមួយយកមកលេង ឬកុមាររើសរឿងនិទានណាដែលកុមារចង់ស្តាប់ជាងគេ។ល។ ការសម្រេចចិត្តរបស់កុមារ ត្រូវកើតឡើងដោយមិនមានឥទ្ធិពលពីនរណាម្នាក់ហើយត្រូវទទួលយកពីលោកគ្រូ អ្នកគ្រូ
- អប់រំកុមារឱ្យចេះធ្វើកិច្ចការដោយខ្លួនឯង មិនមែនមានន័យថា កុមារអាចធ្វើអ្វីៗបានដោយស្រេចតែចិត្តដែលកុមារចង់នោះទេ។ ទាំងនៅតាមសាលាមត្តេយ្យសិក្សា ឬសាលាបឋមសិក្សា តែងតែមានបទបញ្ជាផ្ទៃក្នុងសាលារហូតដល់បទបញ្ជាផ្ទៃក្នុងតាមថ្នាក់ទៀតផង ដែលទាមទារឱ្យកុមារត្រូវគោរពនិងអនុវត្តតាមឱ្យខានតែបាន។ សម្រាប់កុមារគ្រប់វ័យ មុននឹងកុមារសម្រេចចិត្តធ្វើអ្វីមួយ ត្រូវមានការនិយាយគ្នានិងការឯកភាពពីគ្រូជាមុន។ បទបញ្ជានិងវិធានការនានា ជាមគ្គុទ្ទេសក៏សម្រាប់កុមារដឹងថា អ្វីខ្លះដែលកុមារធ្វើបាន និងអ្វីខ្លះដែលកុមារមិនអាចធ្វើបាន

- ការប្រគល់ឱ្យកុមារមានស្មារតីទទួលខុសត្រូវទៅលើអ្វីដែលកុមារធ្វើ និងបានធ្វើនាំឱ្យកុមារមានមោទនភាព និងមានជំនឿជឿជាក់លើសមត្ថភាពខ្លួនឯងកាន់តែខ្លាំង តែសំខាន់គ្រូត្រូវដឹងពីកម្រិតនៃការទទួលខុសត្រូវប៉ុណ្ណាដែលកុមារអាចទទួលធ្វើបាន។ ឧទាហរណ៍ៈ កុមារទទួលខុសត្រូវជាប្រធានថ្នាក់ ឬដឹកនាំកុមារក្នុងក្រុមជួយកុមាររៀនខ្សោយជាងខ្លួន ឬកុមារជួយធ្វើបន្លែសម្រាប់អាហារថ្ងៃត្រង់ បើសាលាមានសេវានេះ។ល។ ជាការពិត ការងារដែលកុមារទទួលធ្វើពិតជាមិនដូចលោកគ្រូ អ្នកគ្រូធ្វើខ្លួនឯងទេ ដូចជា កុមារត្រូវការពេលយូរជាងជាដើម។ ទោះជាយ៉ាងណាក៏ដោយ លោកគ្រូ អ្នកគ្រូ គួរតែផ្តល់ឱកាសឱ្យកុមារធ្វើការងារដោយខ្លួនឯងឱ្យបានច្រើន

- អប់រំកុមារឱ្យចេះធ្វើកិច្ចដោយខ្លួនឯង គឺអប់រំកុមារអាចចេះដោះស្រាយបញ្ហាដោយខ្លួនឯង។ លោកគ្រូ អ្នកគ្រូចូលជួយ លុះត្រាពេលមើលឃើញថាកុមារមិនអាចដោះស្រាយបញ្ហា ឬជម្លោះដោយខ្លួនឯង ឬមានសំណូមពរពីកុមារ។ ជាការពិត តាមរយៈការសង្កេត បើលោកគ្រូ អ្នកគ្រូមើលឃើញថាត្រូវចូលជួយកុមារ ជៀសវាងកុំឱ្យមានគ្រោះថ្នាក់ លោកគ្រូ អ្នកគ្រូត្រូវចូលជួយដោយមិនចាំបាច់មានសំណូមពរឱ្យជួយពីកុមារនោះទេ។ តាមរយៈវិធានការនេះកុមារមានឱកាសរៀនចេះសម្របសម្រួលបញ្ហា ឬជម្លោះដោយខ្លួនឯង និងចេះបកស្រាយការពារខ្លួន ឬដកខ្លួនចេញពីជម្លោះបើដឹងថាខ្លួនបានធ្វើអ្វីមួយមិនត្រឹមត្រូវ

- អប់រំកុមារឱ្យចេះធ្វើកិច្ចដោយខ្លួនឯងគឺ លើកទឹកចិត្តកុមារឱ្យមានភាពក្លាហាន មានអារម្មណ៍និងជឿជាក់លើខ្លួនឯង។ បើកុមារមានបញ្ហា លោកគ្រូ អ្នកត្រូវធ្វើយ៉ាងណាឱ្យកុមារមានអារម្មណ៍ថា មានអ្នកជួយនិងមិនទទួលបានការស្តីបន្ទោស។

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួនស្តីពីការអប់រំសមត្ថភាព ជំនាញទន់ «ចេះធ្វើកិច្ចការដោយខ្លួនឯង»៖

- អប់រំកុមារឱ្យចេះពាក់ស្បែកជើង ស្លៀកពាក់ និងផ្លាស់ប្តូរសំលៀកបំពាក់ពេលទៅរៀន និងមកពីរៀនវិញដោយខ្លួនឯង
- ធ្វើកិច្ចដែលគ្រូដាក់ឱ្យធ្វើ រៀបចំរបស់របរដែលជាកម្មសិទ្ធិរបស់ខ្លួនដាក់ចូលកាបូបសម្រាប់ទៅរៀន និងមុនពេលចេញទៅផ្ទះដោយខ្លួនឯង
- សម្អាតរាងកាយ និងចេះប្រើប្រាស់បង្គន់អនាម័យដោយខ្លួនឯង
- ញ៉ាំចំណីអាហារដោយខ្លួនឯង មិនចាំបាច់មានអ្នកបញ្ចុក និងកុមារចេះសម្រេចដោយខ្លួនឯងនូវបរិមាណអាហារដែលកុមារចង់ញ៉ាំ
- កុមារចេះរៀបចំរបស់របរដែលកុមារយកលេងនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ដាក់ទៅកន្លែងដើមវិញដោយខ្លួនឯង។ល។

**សមត្ថភាពចេះធ្វើកិច្ចការដោយខ្លួនឯងរបស់កុមារម្នាក់ៗខុសៗគ្នាអាស្រ័យទៅនឹងអាយុ និងការអភិវឌ្ឍរបស់កុមារ។ លោកគ្រូ អ្នកគ្រូ ត្រូវគិតគូរ រិះរកគ្រប់មធ្យោបាយអប់រំសមត្ថភាពនេះដល់កុមារឱ្យទទួលបានគ្រប់ៗគ្នា។**

## ៦.៧- កុមារមានស្មារតីទទួលខុសត្រូវលើខ្លួនឯង

អប់រំកុមារឱ្យមានស្មារតីទទួលខុសត្រូវលើខ្លួនឯង មានន័យថា ឱ្យកុមារចេះធ្វើកិច្ចការដោយខ្លួនឯង យ៉ាងសកម្មទាំងពេលរៀន ពេលលេង និងធ្វើកិច្ចការសាលា ហើយកុមារមានវិធានការលើរាល់ភាពមិនប្រក្រតីដែលកើតឡើងពីទង្វើរបស់ខ្លួន។

កុមារមានស្មារតីទទួលខុសត្រូវខ្លួនឯង តែងតែមានការប្តេជ្ញាចិត្តខ្ពស់ ហ៊ានប្រឈមមុខជាមួយនឹងទង្វើដែលខ្លួនបានធ្វើ។

កម្រិតឱ្យកុមារទទួលខុសនិងត្រូវនៅតាមគ្រួសារ ខុសពីនៅសាលាមត្តេយ្យ និងខុសពីនៅសាលាបឋម។ អ្វីដែលសំខាន់ ការកំណត់ឱ្យកុមារទទួលខុសនិងត្រូវ អ្នកពាក់ព័ន្ធការងារអប់រំកុមារ ត្រូវធ្វើយ៉ាងណាមិនឱ្យកុមារមានភាពភ័យខ្លាច មានជំនឿជឿជាក់ទៅលើឪពុកម្តាយ លោកគ្រូ អ្នកគ្រូថានឹងមិនមានអ្វីនឹងកើតឡើងចំពោះកុមារ។ មួយវិញទៀត ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ ត្រូវដឹងថាកុមារត្រូវការពេលវេលា មានការអត់ធ្មត់ នៅពេលកុមារធ្វើអ្វីមួយដោយខ្លួនឯង និងសន្យាថាកុមារទទួលបានជំនួយ បើកុមារមានសំណូមពរ។

ខាងក្រោមនេះ ជាឧទាហរណ៍កុមាររៀនទទួលខុសនិងត្រូវ ជាបន្តបន្ទាប់៖

- ការងារក្នុងផ្ទះ រួមមានយកសំរាមដាក់មុខផ្ទះដើម្បីឱ្យក្រុមហ៊ុនប្រមូលនិងដឹកជញ្ជូនចេញតាមពេលកំណត់។ បត់និងរៀបចំសំលៀកបំពាក់របស់ខ្លួនដាក់ចូលក្នុងទូ ឬរៀបចំសំលៀកបំពាក់ប្រឡាក់ទុកមួយកន្លែងសម្រាប់ប្រមូលយកទៅបោកគក់។ល។
- រាល់ពេលមុននិងក្រោយបាយ កុមារជួយរៀបចំតុបាយ ចានឆ្នាំង។ បើកុមារអាចធ្វើបានជួយការងារដាំស្ល
- សម្អាតខ្លួនប្រាណ ប្រើប្រាស់បន្ទប់អនាម័យដោយខ្លួនឯង
- ជួយមើលថែទាំសត្វក្នុងផ្ទះបើមាន
- ជួយការងារថែសួននៅសាលាមត្តេយ្យ និងបឋមសិក្សា
- គោរពនិងជួយដល់អ្នកដទៃ
- មិនប៉ះពាល់របស់របរអ្នកដទៃ
- ចូលរួមគោរពវិន័យ បទបញ្ជាផ្ទៃក្នុងសាលា និងបទបញ្ជាផ្ទៃក្នុងថ្នាក់

- ចូលរួមរៀបចំ និងអនុវត្តការងារសិក្សាជួយដល់កុមារទន់ខ្សោយចាប់ពីថ្នាក់កម្រិតខ្ពស់ឡើងទៅ
- ចូលរួមធ្វើការងារជាក្រុម
- គោរពរាល់គោលការណ៍ពេលសន្ទនា និងពិភាក្សា
- មិនប្រព្រឹត្តអំពើហិង្សា ទាំងពាក្យសំដី និងកាយវិការ
- មិនរើសអើង ដោយគោរពនិងឱ្យតម្លៃ ទៅលើយេនឌ័រ សាសនា និងវប្បធម៌ខុសៗគ្នា។ល។

## ៦.៨- កុមារចេះលើកទឹកចិត្តខ្លួនឯង

ការចេះលើកទឹកចិត្តនិងផ្តល់កម្លាំងចិត្តខ្លួនឯង ជាថាមពលពីខាងក្នុង ដែលនាំឱ្យកុមារពេញចិត្ត សប្បាយចិត្ត ស្ម័គ្រចិត្ត ដោយប្រុងប្រយ័ត្នក្នុងការបំពេញភារកិច្ចនិងបំណងរបស់ខ្លួន។ កុមារមានការលើកទឹកចិត្តខ្លួនឯង ខិតខំប្រឹងប្រែងបំពេញភារកិច្ចអ្វីមួយ លុះត្រាតែកុមារពេញចិត្តនឹងភារកិច្ចនោះ បើមិនដូច្នោះទេ ការខិតខំប្រឹងប្រែងរបស់កុមារមិនមែនជាថាមពលដែលចេញពីក្នុងខ្លួនកុមារឡើយ។

ទោះជាការចេះលើកទឹកចិត្តនិងឱ្យកម្លាំងចិត្តខ្លួនឯង កើតចេញពីថាមពលខាងក្នុងរបស់កុមារម្នាក់ៗក៏ដោយ ក៏យើងអាចជួយកុមារបានដែរ ដូចជា៖

- លើកទឹកចិត្តនាំឱ្យកុមារមានសុទិដ្ឋិនិយមជានិច្ច ដោយបង្ហាញពីអារម្មណ៍របស់យើងដល់កុមារ ថាយើងមានជំនឿលើកុមារ  អាចធ្វើបាន ហើយបើមានបញ្ហាកុមារក៏អាចដោះស្រាយបញ្ហាដោយខ្លួនឯងបានផងដែរ
- លើកទឹកចិត្តកុមារឱ្យមានការប្រឹងប្រែងឡើង តាមរយៈការសរសើរ ទទួលស្គាល់ស្នាដៃកុមារដែលធ្វើបាន

- លើកទឹកចិត្តកុមារឱ្យទទួលស្គាល់កំហុស តាមរយៈការពន្យល់កុមារថា នរណាក៏តែងតែមានកំហុស តែយើងត្រូវចេះរៀនពីកំហុស ដើម្បីផ្លាស់ប្តូរ និងអភិវឌ្ឍខ្លួនបន្ត
- លើកទឹកចិត្តកុមារឱ្យស្រឡាញ់ការសិក្សា តាមរយៈដាក់កិច្ចការឱ្យកុមារធ្វើ ដែលពាក់ព័ន្ធទៅនឹងជីវភាពរស់នៅរបស់កុមារ
- ផ្តល់ឱកាសដល់កុមារ ធ្វើកិច្ចការដែលកុមារចូលចិត្ត និងធ្វើទៅបានជោគជ័យ
- កិច្ចការដែលកុមារត្រូវធ្វើ ត្រូវសមស្របទៅនឹងសមត្ថភាពដែលកុមារមានស្រាប់ និងជាតម្រូវការរបស់កុមារ។ល។

## ៦.៩- កុមារចេះធ្វើការសហការ

អប់រំ ពង្រឹងសមត្ថភាព ចេះធ្វើការសហការដល់កុមារមានប្រសិទ្ធភាពខ្លាំង តាមរយៈណែនាំកុមារ លេង រៀន និងធ្វើកិច្ចការជាមួយគ្នា ជាពិសេសពេលកុមារធ្វើការងារជាក្រុម។ សមត្ថភាពសហការធ្វើការងារក្រុម ជាសមត្ថភាពកុមារត្រូវការពេញមួយជីវិត ជាពិសេសពេលកុមារដល់វ័យចូលប្រកបមុខរបរចិញ្ចឹមជីវិត។

សរុបសេចក្តីទៅ ការណែនាំកុមារនៅសាលាមត្តេយ្យ និងសាលាបឋមសិក្សា ឱ្យកុមារលេង រៀន និងសហការធ្វើកិច្ចការជាមួយគ្នា ធ្វើការងារជាក្រុម គឺយើងកំពុងអប់រំកុមារ និងពង្រឹងសមត្ថភាពសហការនេះដល់កុមារច្បាស់ណាស់។

នៅពេលកុមារលេង រៀន និងសហការធ្វើកិច្ចការជាមួយគ្នា ធ្វើការងារក្រុម កុមារទទួលបានការពង្រឹងលើសមត្ថភាពជាច្រើនទៀត ឧទាហរណ៍៖

- កុមារចេះធ្វើទំនាក់ទំនងជាមួយកុមារដទៃទៀត ដូចជាកុមារទម្លាប់រៀនស្តាប់ ពេលកុមារដទៃកំពុងនិយាយទៅកាន់ខ្លួន ឬទៅកាន់ក្រុមទាំងមូល ប្រកបទៅដោយសមត្ថភាពអត់ធ្មត់។ កុមាររៀនចេះសួរសំណួរ បើកុមារ

មានចម្ងល់ ចេះបកស្រាយទៅកាន់មិត្តភក្តិ ឬទៅកាន់ក្រុមទាំងមូល ហើយចេះសុំទោស ពេលកុមារធ្វើអ្វីមួយមិនល្អទៅកាន់មិត្តភក្តិរបស់ខ្លួន។ល។

- កុមារចេះពិភាក្សាជាមួយគ្នារកដំណោះស្រាយលើបញ្ហាដែលនាំឱ្យកុមារមានទម្លាប់ និងស្គាល់នូវអ្វីដែលហៅថា ស្រុះស្រួល និងឯកភាពគ្នា
- កុមាររៀនចេះទទួលនិងស្គាល់ភារកិច្ច ព្រមទាំងតួនាទី
- កុមាររៀនចេះចែករំលែក មិនរើសអើង ចេះជួយគ្នាទៅវិញទៅមក
- កុមាររៀនចេះបង្ហាញពីអារម្មណ៍របស់ខ្លួនដោយប្រុងប្រយ័ត្ន និងស្គាល់អារម្មណ៍កុមារដទៃ
- កុមាររៀនស្គាល់ពីបំណង និងតម្រូវការរបស់កុមារដទៃ និងត្រៀមខ្លួនបានល្អ ដើម្បីសម្របខ្លួន រកផ្លូវមួយកណ្តាលជាមួយគ្នា រក្សាបំណង និងតម្រូវការ ដែលអាចទទួលយកបានរៀងៗខ្លួន និងកាត់បន្ថយទំនាស់
- កុមាររៀនសហការបង្កើតគំនិត និងអនុវត្តគំនិតឱ្យក្លាយជាការពិត
- កុមាររៀនចេះលើកទឹកចិត្ត កម្លាំងចិត្ត និងគាំទ្រជួយគ្នាទៅវិញទៅមក។ល។

## ៦.១០- កុមារចេះធ្វើការប្រាស្រ័យទាក់ទង

និយមន័យនៃសមត្ថភាពប្រាស្រ័យទាក់ទងដែលងាយយល់ គឺជាសមត្ថភាពក្នុងការបកស្រាយឱ្យដៃគូសន្ទនាងាយយល់ពីបំណងខ្លឹមសារ សាររបស់ខ្លួនដែលចង់ផ្សព្វផ្សាយ។ ប្រាស្រ័យទាក់ទង ជាសមត្ថភាពសង្គមដែលពលរដ្ឋគ្រប់រូបចាំបាច់ត្រូវមាន ត្រូវទទួលបានតាមរយៈការអប់រំពេញមួយជីវិត។

កុមារដែលមានសមត្ថភាពនេះ មិនមានការលំបាក មិនត្រឹមតែក្នុងការបកស្រាយពីគំនិតនិងបំណងរបស់ខ្លួន ដែលចង់ចែករំលែកប៉ុណ្ណោះទេ ថែមទាំងងាយយល់ពីការបកស្រាយពីគំនិត និងបំណងដៃគូសន្ទនាចង់ចែករំលែកទៀតផង។

ជាការពិតណាស់ ប្រាស័យទាក់ទងដំណើរការទៅបានល្អ អាស្រ័យទៅនឹងសមត្ថភាពពាក់ព័ន្ធជាច្រើនទៀត និងកម្រិតនៃការគោរពគោលការណ៍មួយចំនួនរួមមាន៖

- ចាប់ផ្ដើមការសន្ទនា តាមរយៈការបង្កើតនូវមានស្និទ្ធស្នាលគ្នាជាមុន
- កំណត់គោលដៅ ឬវត្ថុបំណងនៃការសន្ទនាច្បាស់លាស់
- ពេលពិភាក្សាគ្នា ត្រូវបង្ហាញពីការយកចិត្តទុកដាក់ តាមរយៈការខិតខំត្រងត្រាប់ស្ដាប់ បែរមុខទៅរកដៃគូសន្ទនា
- ឃ្លានិយាយខ្លី ងាយយល់ និងមិនវែងពេក ដោយប្រើពាក្យសមរម្យ
- គោរពដៃគូសន្ទនា ទុកពេលវេលាគ្រប់គ្រាន់សម្រាប់ដៃគូបកស្រាយ ដោយមិននិយាយកាត់
- បង្ហាញនូវភាពជឿជាក់លើខ្លួនឯង ស្មោះត្រង់លើខ្លួនឯង តែមិនត្រូវបង្ហាញពីអាកប្បកិរិយា ថាខ្លួនឯងចេះជាងដៃគូនោះទេ
- ប្រយ័ត្ន រាល់កាយវិការ និងទឹកមុខពេលសន្ទនា។ល។

អប់រំនិងពង្រឹងសមត្ថភាពប្រាស្រ័យទាក់ទងដល់កុមារអាចធ្វើទៅបាននៅគ្រប់ទីកន្លែង មិនថានៅផ្ទះជាមួយឪពុកម្ដាយ ឬនៅសាលាមត្តេយ្យ ឬនៅតាមភូមិសិក្សាជាបន្តបន្ទាប់នោះទេ។

នៅសាលាមត្តេយ្យនិងសាលាបឋមសិក្សា គ្រូមានឱកាសជាច្រើនលើការងារអប់រំ និងពង្រឹងសមត្ថភាពប្រាស្រ័យទាក់ទងដល់កុមារក្នុងទំរង់ផ្សេងៗជាច្រើន ដូចជា៖

- ឧស្សាហ៍ណែនាំកុមារ ជួបជុំគ្នា ពិភាក្សាលើប្រធានបទ ឬស្ដីពីស្ថានការណ៍មួយដែលកើតឡើង

- អានអត្ថបទ ឬរឿងនិទានណាមួយឱ្យកុមារស្តាប់ ហើយពិភាក្សាជាមួយកុមារលើខ្លឹមសាររឿងនិទាន ដែលកុមារបានស្តាប់រួច
- ពិភាក្សាជាក្រុម ស្តីពី រឿងផ្សេងៗ ពាក់ព័ន្ធទៅនឹងការសិក្សារបស់កុមារ ឬទិដ្ឋភាពដែលកុមារបានជួបប្រទះ
- នាំកុមារលេងសម្តែងតួអង្គ លេងល្បែងបង្កើតពាក្យ។ អញ្ជើញឪពុកម្តាយកុមារ មកនិយាយបកស្រាយហេតុការណ៍ណាមួយដែលពាក់ព័ន្ធទៅការអប់រំកុមារ ដោយបង្កលក្ខណៈឱ្យមានការពិភាក្សា
- ថត វីដេអូ ពេលកុមារពិភាក្សា ឬលេងល្បែង ហើយយកមកចាក់មើលឡើងវិញ ឱ្យកុមារពិភាក្សាគ្នា។

**វិធីសាស្ត្រដ៏មានប្រសិទ្ធិភាពក្នុងការអប់រំ និងពង្រឹងសមត្ថភាពប្រាស្រ័យទាក់ទង គឺត្រូវធ្វើជាគំរូល្អសម្រាប់កុមារ គ្រាប់តាម។**

## ៦.១១- កុមារចេះយល់អារម្មណ៍អ្នកដទៃ

កុមារដែលមានសមត្ថភាពនេះ អាចយកអារម្មណ៍អ្នកដទៃមកដាក់ក្នុងខ្លួន ទាំងអារម្មណ៍សប្បាយ អារម្មណ៍កើតទុក្ខ ហើយធ្វើការឈ្វេងយល់។ កុមារបែបនេះជាកុមារចេះមានការអាណិតអាសូរ គោរពអ្នកដទៃ ត្រៀមខ្លួនបានល្អ ក្នុងការជួយយកអាសាអ្នកដទៃ បង្កើតចំណងមិត្តភាព ធ្វើការងារជាក្រុម ដោះស្រាយបញ្ហាងាយនិងចូលចិត្តធ្វើការងារសង្គម។

កុមារដែលមានសមត្ថភាពនេះ តែងតែ៖

- យល់អារម្មណ៍សុខទុក្ខរបស់កុមារដទៃទៀត តាមរយៈការសង្កេតទៅលើទឹកមុខ សកម្មភាពកាយវិការ ភាសា។ល។

- រៀបចំខ្លួនបានល្អ ទទួលយកស្ថានការដែលកើតឡើង ចូលរួមរំលែកទុក្ខ ចំពោះអារម្មណ៍កើតទុក្ខ ចូលរួមសប្បាយចំពោះអារម្មណ៍សប្បាយ
- រៀបចំខ្លួនបានល្អ ជួយដល់កុមារដទៃ។ល។

អប់រំកុមារឱ្យមានសមត្ថភាពសង្គមនេះ អាចធ្វើឡើងតាមអាយុកុមារ និងវិធីសាស្ត្រជាច្រើន ដូចជា៖

- អានរឿងនិទានឱ្យកុមារស្ដាប់ ដោយអ្នកអានចេះសម្ដែងនិងចូលតួក្នុងសាច់រឿង
- លើកឡើងពិភាក្សាពីស្ថានភាពនៅក្នុងថ្នាក់ ក្នុងក្រុម នៅពេលកុមារជួបនូវស្ថានភាពអ្វីមួយ ទាំងស្ថានភាពសប្បាយ និងភ័យខ្លាច
- ពិភាក្សាដោយប្រុងប្រយ័ត្នរកមូលហេតុ ពេលកុមារម្នាក់នៅក្នុងថ្នាក់ មានអារម្មណ៍មិនល្អ
- ពិភាក្សាជាមួយកុមារ ពេលកុមារម្នាក់ត្រូវការជំនួយ
- សហការក្នុងក្រុម ធ្វើសកម្មភាពមនុស្សធម៌ជួយដល់អ្នកដែលកំពុងតែលំបាក ដូចជាជួយកុមារមកពីគ្រួសារក្រីក្រ
- សហការក្នុងក្រុម ស្វែងយល់ពីហេតុផលកើតឡើងនិងស្វែងរកមធ្យោបាយដោះស្រាយ ឬជៀសវាងបញ្ហា
- ចូលរួមអបអរ ចំពោះកុមារដទៃដែលកំពុងមានអារម្មណ៍ល្អ
- បង្កើតនូវក្ដីទុកចិត្តដល់កុមារដទៃ ដើម្បីបង្ហាញពីអារម្មណ៍យកចិត្តទុកដាក់ កុំឱ្យកុមារមានភាពភ័យខ្លាច ពេលកុមារត្រូវការជំនួយ។

## ៦.១២- កុមារទទួលការទិតៀន/ការរិះគន់ពីអ្នកដទៃ

ទិតៀនមានទាំងទិតៀនខ្លួនឯង (ស្វ័យទិតៀន) និងទិតៀនពីអ្នកដទៃ ពិតជាសមត្ថភាព ពិបាកសម្រាប់មនុស្សគ្រប់រូប មិនថាក្មេងឬមនុស្សពេញវ័យ។ ទិតៀនអាចមានលក្ខណៈ វិជ្ជមាន អវិជ្ជមាន ស្ដីបន្ទោស ឬកសាង។

ការទិតៀនលក្ខណៈវិជ្ជមានឬបែបស្ថាបនា ជាបំណងការអប់រំដល់កុមារ។ បំណងទិតៀនបែបស្ថាបនា គឺមានតែមួយគឺឱ្យយើងដឹងខ្លួន ត្រៀមខ្លួន ជៀសវាងកើតបញ្ហា ឬសម្រាប់ឱកាសកែប្រែ អភិវឌ្ឍខ្លួនទៅរកភាពវិជ្ជមាន។

របៀបទិតៀនបែបស្ថាបនា ជាសកម្មភាពកើតឡើង តាមរយៈការលើកសរសើរជាមុន និងការណែនាំកែលំអជាចុងក្រោយ។

ទទួលការទិតៀនពីអ្នកដទៃមនុស្សទូទៅពិបាកនឹងធ្វើបាន តែវាជាបច្ច័យសម្រាប់ឱ្យយើងយកមកពិចារណា ដើម្បីកែប្រែ អភិវឌ្ឍខ្លួនទៅរកភាពវិជ្ជមាន និងរីកចម្រើនបាន។

ទទួលយកការទិតៀនពីអ្នកដទៃ សម្រាប់កុមារមានការលំបាកជាងមនុស្សពេញវ័យ។ ដូចនេះសំខាន់ណាស់ កុមារត្រូវរៀនចេះទទួលការទិតៀនពីអ្នកដទៃបន្តិចម្ដងៗ និងពេញមួយជីវិត។

កុមារត្រូវយល់ថា ការទិតៀនបែបស្ថាបនាគឺជាមតិ ឬយោបល់របស់អ្នកដទៃក្នុងបំណងល្អ ជាឱកាសឱ្យយើងកែប្រែកំហុសទាន់ពេលវេលា ។

វិធីសាស្ត្រទិតៀនដល់កុមារ ក្នុងបំណងស្ថាបនាគឺ៖

- លើកឡើងនូវគុណសម្បត្តិមុន រួចបង្ហាញពីអ្វីខ្លះដែលចំណុចខ្វះខាតកុមារត្រូវកែប្រែ ជៀសវាង ឬធ្វើឱ្យបានល្អជាងមុន
- បញ្ជាក់ឱ្យបានច្បាស់ពីបំណងទិតៀន

- គ្រប់គ្រងអារម្មណ៍ឱ្យបានល្អ បង្ហាញពីអារម្មណ៍យល់យោគ ប្រកាន់ខ្ជាប់ឥរិយាបថ គោរព ឱ្យតម្លៃ កុមារកំពុងទទួលការទិតៀន
- ជៀសវាងនិយាយអ្វីដែលមិនបានការ។ បកស្រាយ ថាអ្វីដែលលើកឡើងគ្រាន់តែជាយោបល់ មិនមែនដាក់កំហិតត្រូវធ្វើ។ល។

វិធីសាស្ត្របើកចិត្តទូលាយទទួលយកការទិតៀនពីអ្នកដទៃ៖
- ប្រុងប្រយ័ត្នស្តាប់មិតយោបល់របស់អ្នកទិតៀន
- ធ្វើអារម្មណ៍បានល្អ កុំគិតថាខ្លួនគេកំពុងត្រូវគេវាយប្រហារ
- មានការគិតគូរ និងវិភាគឱ្យបានដិតដល់លើខ្លឹមសារទិតៀន
- ត្រូវយល់ថាគេមានបំណងចង់ជួយយើង
- សួរនាំ បើមិនយល់ត្រង់ណា
- កុំបញ្ចេញអាកប្បកិរិយា ការពារទង្វើរបស់ខ្លួនមិនសំហេតុផល
- អរគុណដល់អ្នកទិតៀន។ល។

## ៧- សមត្ថភាពអាជីពជាគ្រូបង្រៀន

បុគ្គលមានអាជីពជាគ្រូបង្រៀន ត្រូវមានសមត្ថភាព ឆ្លើយទៅនឹងសំណួរខាងក្រោមនេះឱ្យបាន៖
- តើសមត្ថភាពមានស្រាប់របស់កុមារដែលជាសិស្សក្នុងថ្នាក់របស់ខ្លួនមានអ្វីខ្លះ?
- តើតាមមុខវិជ្ជានីមួយៗដែលត្រូវបង្រៀនដល់កុមារ មានប្រធានបទ ខ្លឹមសារមេរៀនអ្វីខ្លះ? អ្វីខ្លះជាលទ្ធផលរំពឹងទុក? រួមទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា

- តើទីកន្លែងបង្រៀនកុមារមានស្ថានភាដូចម្តេចដែរ ទូលាយឬចង្អៀត ស្របតាមបទដ្ឋានអប់រំឬអត់? មានសម្ភារៈឧបទេសអ្វីខ្លះសម្រាប់បង្រៀន?
- តើគ្រូត្រូវជ្រើសរើសយកគោលវិធីណាមកប្រើប្រាស់ ក្នុងការបង្រៀនដើម្បីអប់រំកុមារឱ្យកុមារទទួលបាននូវសម្បទាទាំងបីតាមការរំពឹងទុក?
- តើគ្រូត្រូវប្រើ និងមានសមត្ថភាពអ្វីខ្លះ សម្រាប់យកទៅបង្រៀនកុមារខាងលើ?

## ៨- វិធីសាស្ត្របង្រៀន តាមគោលវិធីគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល

ការងារអប់រំមិនមែនជាការរត់ប្រណាំងចំងាយ១០០ម៉ែត្រនោះទេ តែវាជាការរត់ម៉ារ៉ាតុង ដែលទាមទារឱ្យមានពេលវេលាគ្រប់គ្រាន់ ទាំងសម្រាប់ការផ្តល់ចំណេះដឹង ពង្រឹងបំណិនក្នុងការប្រើប្រាស់ចំណេះដឹង និងអប់រំកុមារឱ្យមានឥរិយាបថល្អដែលពលរដ្ឋត្រូវការសម្រាប់រស់នៅក្នុងសង្គមប្រកបដោយសុខដុមនីយកម្មជាមួយអ្នកដទៃ។

ការងារអប់រំត្រូវធ្វើនៅទីកន្លែងសមស្រប និងមានការរៀបចំ ចាត់ចែងតាមនិយាមគរុកោសល្យ និងអាយុ វ័យរបស់កុមារ។

នៅព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានបង្កើតកន្លែងអប់រំចំណេះដឹងទូទៅដល់កុមារ មាននៅសាលាមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សា។

ការអប់រំកុមារលើចរិយាសម្បទាមានភាពងាយស្រួល តែពេលកុមារនៅតូចមានអាយុនៅតិច។ ដូច្នេះកន្លែងដែលងាយស្រួលអប់រំជំនាញទន់ ឬចរិយាសម្បទាដល់កុមារ គឺនៅតាមផ្ទះជាមួយឪពុកម្តាយ នៅសាលាមត្តេយ្យ និងបឋមសិក្សា។

វិធីសាស្ត្រអប់រំកុមារ ដែលគេនិយមអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា មានការអប់រំតាមគោលវិធីគ្រូមជ្ឈមណ្ឌល និងគោលវិធីសិស្សមជ្ឈមណ្ឌល។

អំពីគោលវិធីទាំងពីរនេះ យើងពិតជាមិនអាចនិយាយបានថា គោលវិធីណាល្អជាងគោលវិធីណាបានទេ។ សំខាន់អ្នកអប់រំ ឬអ្នកមានអាជីពជាអ្នកអប់រំ ជាពិសេសគ្រូបង្រៀនត្រូវដឹងនិងច្បាស់ខ្លួនឯងថា ពេលណាគាត់ត្រូវប្រើគោលវិធីគ្រូមជ្ឈមណ្ឌល និងពេលណាត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល។

ខាងក្រោមនេះជាការបកស្រាយដោយសង្ខេប អំពីគោលវិធីអប់រំទាំងពីរនេះទៅលើចរិតលក្ខណៈនិងភាពងាយស្រួល ព្រមទាំងការលំបាកក្នុងបរិបទប្រទេសកម្ពុជា។

## ៨.១- គោលវិធីគ្រូមជ្ឈមណ្ឌល

គោលវិធីគ្រូមជ្ឈមណ្ឌល ជាទម្រង់នៃការបង្រៀន ដែលឆន្ទៈនៃការខិតខំប្រឹងប្រែង និងរាល់សេចក្តីសម្រេចចិត្ត រួមទាំងខ្លឹមសារមេរៀនសម្រាប់បង្រៀនស្ថិតនៅលើគ្រូទាំងស្រុង។ គ្រូដើរតួនាទីសំខាន់ក្នុងដំណើរការបង្រៀន និងការរៀនសូត្ររបស់កុមារ។

នៅក្នុងថ្នាក់ ពេលគ្រូកំពុងបង្រៀននិងពន្យល់ គ្រូមានវត្តមានស្ទើរតែគ្រប់ពេលនៅពីមុខកុមារ ចំណែកឯកុមារអង្គុយជាជួរ បែរមុខទៅរកគ្រូ សម្លឹងទៅរកគ្រូ រក្សាភាពស្ងៀមស្ងាត់ ខំប្រឹងស្តាប់ មិនអនុញ្ញាតឱ្យនិយាយជជែកសួរគ្នាទៅវិញទៅមក ព្យាយាមទទួលយករាល់ខ្លឹមសារដែលគ្រូកំពុងបង្រៀន។

អ្នកឯកទេសនៃការអប់រំបានរកឃើញថា ការអនុវត្តវិធីបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌលនេះ បើគ្រូពន្យល់កុមារតែតាមរយៈផ្ទាល់មាត់តែមួយ លទ្ធផលសិក្សារបស់កុមារទទួលបានត្រឹមតែ៨%នៃមេរៀនប៉ុណ្ណោះ។ ការបង្រៀនធ្វើឡើងតាមរយៈការពន្យល់ផ្ទាល់មាត់ផង មានរូបភាព គំនូរ សម្ភារៈឧបទេសផ្សេងៗទៀត

និងមានការអនុវត្តជាក់ស្តែងបន្ថែម នោះលទ្ធផលសិក្សារបស់កុមារកើនឡើងដល់ទៅ៣ដង។ កុមារនឹងរៀនបានកាន់តែច្រើន ពេលណាកុមារកត់ត្រាខ្លឹមសារ ដែលខ្លួនបានរៀន និងកំពុងរៀន។ កំណត់ត្រានេះ ទុកសម្រាប់កុមាររៀនសារឡើងវិញ ត្រូវយល់ចំពោះសំណេរខ្លួនឯង ហើយបើមិនយល់កន្លែងណា កុមារត្រូវហ៊ានសួរគ្រូ។ ពេលនោះកុមារអាចទទួល និងយល់បានចំណេះដឹងពីគ្រូរហូតដល់៨៥%។

## ៨.១.១- ភាពងាយស្រួល និងគុណសម្បត្តិ

ភាពងាយស្រួលក្នុងការអនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌលៈ

- គ្រូងាយសម្រេចគោលដៅនៃការសិក្សាថ្នាក់ជាតិ ទាំងខ្លឹមសារ និងពេលវេលា
- ដោយសារកុមារមានវិន័យ អង្គុយបែរមុខទៅគ្រូដោយស្ងៀមស្ងាត់ និងត្រៀមខ្លួនត្រងត្រាប់ស្តាប់គ្រូបង្រៀននិងណែនាំ ទោះចំនួនកុមារលើសពីនិយាមគរុកោសល្យបន្តិចបន្តួចក៏ដោយ គ្រូមិនសូវមានអារម្មណ៍តានតឹង។ គ្រូមានទំនុកចិត្តក្នុងការបង្រៀន
- ក្នុងរយៈពេលខ្លី គ្រូអាចផ្តល់និងចែករំលែកចំណេះដឹងបានច្រើនដល់កុមារ។ តែមិនប្រាកដថា កុមារយល់និងអាចយកចំណេះដឹងនេះទៅអនុវត្តបានជោគជ័យប៉ុណ្ណោះទេ
- ប្រើប្រាស់សម្ភារៈឧបទេសតិចៗល។

អនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌលផ្តល់នូវគុណសម្បត្តិមួយចំនួនដូចខាងក្រោមៈ

- មានប្រសិទ្ធភាព សម្រាប់គ្រូដែលត្រូវរំលឹកមេរៀន ត្រៀមមុនពេលកុមារប្រឡង
- សម្រាប់គ្រូដែលបានទទួលការអប់រំគរុកោសល្យ អាជីពជាគ្រូបន្តិចបន្តួច ក៏អាចបង្រៀនកុមារ ដើម្បីផ្តល់ចំណេះដឹងបានដែរ

- ជំនាញទន់ឯករាជ្យម្ចាស់ការ ស្វ័យសិក្សា និងធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង។ល។ ត្រូវបានអប់រំនិងពង្រឹង។

## ៨.១.២- ការលំបាក និងគុណវិបត្តិ

ប្រៀបធៀបទៅនឹងទំហំនៃភាពងាយស្រួល ក្នុងការអនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌល គ្រូពិតជាមិនមានចម្លើយស្តីពីការលំបាកច្រើនឡើយ។ អ្វីដែលគ្រូតែងតែត្អូញត្អែរនោះគឺ គាត់នឿយហត់ ដោយសារគ្រូត្រូវនិយាយ បកស្រាយច្រើនតែម្នាក់ឯង។ ពេលគ្រូអនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌល ការលំបាកភាគច្រើនធ្លាក់ទៅលើកុមារជាសិស្សវិញ ដូចជា៖

- កុមារទទួលបានឱកាសតិចបំផុតក្នុងការសួរសំណួរ ជជែកពិភាក្សាជាមួយមិត្តរួមថ្នាក់ ឱ្យជួយបំភ្លឺនិងបកស្រាយរាល់ចម្ងល់ដែលខ្លួនមាន
- ការបញ្ចេញមតិយោបល់ ផ្តល់គំនិតរបស់កុមារមិនត្រូវបានយកចិត្តទុកដាក់។ល។

គុណវិបត្តិផ្សេងទៀតពេលគ្រូអនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌលរួមមាន៖

- សមត្ថភាពកុមារមានស្រាប់ និងតម្រូវការកុមារ មិនត្រូវបានយកចិត្តទុកដាក់
- ការអប់រំជំនាញទន់ (បំណិនសម្បទា និងចរិយាសម្បទា) ដល់កុមារមានកម្រឹតតិចបំផុត
- ពេលកុមារត្រូវចូលទៅរស់នៅក្នុងសង្គមធំ កុមារអាចមានការលំបាកក្នុងការប្រកួតប្រជែងការងារទីផ្សារទទួលបានជោគជ័យ និងរស់នៅក្នុងសង្គមប្រកបដោយសុខដុមនីយកម្មជាមួយអ្នកដទៃ។ ឧទាហរណ៍ៈ នៅពេលបំពេញការងារ កុមារមិនហ៊ានផ្តល់មតិយោបល់ ប្រកបទៅដោយហេតុផលរង់ចាំតែធ្វើតាមការណែនាំ កុមារបាត់បង់ និងលែងមានឆន្ទៈបណ្តុះនិងបង្កើតគំនិតខ្លួនឯង លែងមានភាពឯករាជ្យម្ចាស់ការ ។ល។

## ៨.២- គោលវិធីសិស្សមជ្ឈមណ្ឌល

គោលវិធីសិស្សមជ្ឈមណ្ឌល ជាទម្រង់បង្រៀននិងរៀន ដោយមានការគិតគូរគ្រប់ជ្រុងជ្រោយ ពិសេសគិតគូរទៅលើតម្រូវការនិងសមត្ថភាពដែលកុមារមានស្រាប់។

នៅក្នុងថ្នាក់រៀន ក្រៅពីត្រងត្រាប់ស្តាប់គ្រូកំពុងបង្រៀននិងណែនាំ កុមារអាចសួរសំណួរ និងបង្កើតចម្លល់ និងអនុញ្ញាតឱ្យមានការចូលរួមបញ្ចេញមតិយោបល់ទៀតផង។ល។

អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល កុមារអង្គុយជាក្រុម ជាពិសេសនៅពេលដែលកុមារទទួលបានកិច្ចការអ្វីមួយដែលតម្រូវឱ្យមានកិច្ចសហការ ដោះស្រាយរួមគ្នា។ ភារកិច្ចរបស់គ្រូនៅពេលនេះ គ្រាន់តែជាអ្នកសម្របសម្រួល មិនរំខានកុមារពេលកុមារកំពុងពិភាក្សា សហការរកដំណោះស្រាយបញ្ហា។ គ្រូចូលជួយកុមារ នៅពេលណាដែលកុមារត្រូវការជំនួយ។

គោលបំណងនៃការអប់រំ និងការសិក្សា តាមគោលវិធីសិស្សមជ្ឈមណ្ឌល ទន្ទឹមនឹងការអប់រំកុមារឱ្យមានចំណេះដឹង កុមាររៀនចេះ និងមានបំណិនអនុវត្តចំណេះដឹង និងមានចរិយាសម្បទាផ្សេងៗទៀតជាច្រើន ដែលកុមារត្រូវការពេញមួយជីវិត។

នៅចន្លោះឆ្នាំ១៨៧០ដល់១៩៥២ មានវេជ្ជបណ្ឌិត និងគរុវិទ្យាម្នាក់ឈ្មោះ Maria Montessori បានរៀបចំកម្មវិធីសិក្សា និងមេរៀនបង្រៀនយោងតាមគោលការណ៍បី តម្រូវការ ចំណាប់អារម្មណ៍ និងសមត្ថភាពរបស់កុមារដែលមានស្រាប់។ គោលវិធីនេះទទួលបានការពេញនិយមជាដំបូងក្នុងការអនុវត្តនៅក្នុងសាលាបឋមសិក្សា។ សព្វថ្ងៃនេះគោលវិធីសិស្សមជ្ឈមណ្ឌល ត្រូវបានទទួលស្គាល់ និងពេញនិយម អនុវត្តដើម្បីអប់រំកុមារនៅមត្តេយ្យនិងតាមសាលាចំណេះទូទៅ។

តាមរយៈការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល សមត្ថភាពនិងជំនាញទន់ជាច្រើន កុមារទទួលបានពីការអប់រំនិងពង្រឹងបន្ថែម។ កុមារត្រូវការថាមពលច្រើន ព្រោះនៅក្នុងថ្នាក់ កុមាររៀនផង និងបង្រៀនផង។ កុមារជាគ្រូ ជួយកុមារដែលមានបញ្ហា និងកុមារជាសិស្ស កាលណាកុមារមិនយល់ខ្លឹមសារមេរៀន ត្រូវការពន្យល់ពីអ្នកដទៃ។

## ៨.២.១- គុណសម្បត្តិ

សមនឹងពាក្យថាសិស្សមជ្ឈមណ្ឌល ក្រៅពីកុមារខិតខំត្រងត្រាប់ស្តាប់គ្រូបង្ហាត់ បង្រៀន កុមារត្រូវបានណែនាំឱ្យចេះធ្វើការងារជាក្រុម សហការរៀនជាក្រុម និងប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកបានល្អ។

អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលផ្តល់នូវគុណសម្បត្តិជាច្រើន ជាពិសេសដល់សិស្ស ដែលជាវត្ថុបំណងនៃការអប់រំក្នុងសតវត្សទី២១ ឧទាហរណ៍៖

- កុមារពេញចិត្ត ស្រឡាញ់ការសិក្សា ព្រោះចំណង់ចំណូលចិត្ត តម្រូវការព្រមទាំងសមត្ថភាពកុមារមានស្រាប់ ត្រូវបានគិតគូ និងយកចិត្តទុកដាក់
- ក្រៅពីរៀនចំណេះដឹងនិងជំនាញតាមរយៈការរៀន លេងនិងធ្វើកិច្ចការជាក្រុម អនុវត្តគម្រោង សមត្ថភាព ឬជំនាញទន់របស់កុមារជាច្រើនត្រូវបានពង្រឹង ដូចជា ការប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម ចាត់ចែង សង្កេត វិភាគ ត្រិះរិះ ពិចារណា សម្រេចចិត្ត ដោះស្រាយបញ្ហាប្រកបដោយស្មារតីទទួលខុសត្រូវ
- ពេលកុមារពេញចិត្ត ស្រឡាញ់ការសិក្សា បំណិនស្វ័យសិក្សាកុមារត្រូវបានលើកស្ទួយ កុមារចេះធ្វើការសិក្សាស្រាវជ្រាវ ហ៊ានសួរនិងបង្កើតចម្លើយ
- កុមាររៀនមានទំនាក់ទំនងសង្គមបានល្អ មានជំនឿជឿជាក់លើសមត្ថភាពខ្លួនឯង កាត់បន្ថយការភ័យខ្លាច ក្លាហានចេះធ្វើអ្វីៗ និងដោះស្រាយបញ្ហាជាច្រើនដោយខ្លួនឯង

- គ្រូទទួលបានបទពិសោធន៍ និងទទួលបានចំណេះដឹងថ្មីៗពីកុមារ។ល។

### ៨.២.២- ការលំបាក គុណវិបត្តិ

ទស្សនៈលោក Reinhard Witzel គរុសាស្ត្រផ្នែកសង្គម ជនជាតិអាល្លឺម៉ង់ យល់ថា គោលវិធីសិស្សមជ្ឈមណ្ឌល មិនមានអ្វីលំបាកធ្ងន់ធ្ងរណាស់ណា រហូតដល់គ្រូពិបាក ឬមិនអាចអនុវត្តបាននោះទេ ទោះជាគ្រូមិនមានសម្ភារៈឧបទេសសិក្សាសម្បូរបែបក៏ដោយ។ សំខាន់គ្រូត្រូវដឹងនិងមានគំនិតច្នៃប្រឌិតគ្រប់គ្រាន់ស្វែងរកកម្មវិធីសិក្សាណាងាយៗ មិនតម្រូវឱ្យមានសម្ភារៈឧបទេសច្រើន ។

ជាការពិតណាស់ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូត្រូវត្រៀមខ្លួន និងធ្វើបច្ចុប្បន្នភាពចំណេះដឹងជានិច្ច ដើម្បីអាចឆ្លើយទៅនឹងរាល់សំណួរ និងចម្ងល់ដែលកុមារមាន។ គ្រូត្រូវស្រឡាញ់ការសិក្សាពេញមួយជីវិត មានសមត្ថភាពចាត់ចែង ជាពិសេសចាត់ចែងពេលវេលា ដើម្បីអាចឆ្លៀតពេលធ្វើការសិក្សា ស្រាវជ្រាវបន្ត និងចូលរួមវគ្គបណ្តុះបណ្តាល ខ្លីនិងវែងឱ្យបានច្រើន។

តាមរយៈការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ការងារដែលគ្រូគិតថាលំបាកមួយទៀត គឺរៀបចំមេរៀន និងខ្លឹមសារបង្រៀន ដោយមានការគិតគូរពីតម្រូវការ ចំណាប់អារម្មណ៍ និងសមត្ថភាពកុមារមានស្រាប់។

យើងបានដឹងទាំងអស់គ្នាដែរហើយថា សមត្ថភាព ជំនាញទន់កុមារ យើងមិនអាចវាស់វែង និងដឹងតាមរយៈការធ្វើការប្រឡងបាននោះទេ។ ដូច្នេះ លោកគ្រូអ្នកគ្រូត្រូវមានបំណិនក្នុងការសង្កេត វាយតម្លៃ ជំនាញទន់លើកុមារជារៀងរាល់ថ្ងៃ និងមានការកត់ត្រាផងដែរ។

មួយវិញទៀត បើអ្នកពាក់ព័ន្ធលើការងារអប់រំទាំងអស់ ទាំងក្នុងនិងក្រៅសាលា មិនមានការឯកភាព និងមិនផ្តល់ទឹកចិត្ត គាំទ្រសកម្មភាពអប់រំកុមារ តាមគោលវិធីសិស្សមជ្ឈមណ្ឌលនេះទេ គ្រូពិតជាលំបាកទទួលបានជោគជ័យក្នុងការ

ណែនាំពង្រឹងជំនាញទន់ដល់កុមារ។ ឧទាហរណ៍ៈ នៅសាលា កុមារទទួលបានការអប់រំឱ្យចេះមានការបញ្ចេញមតិ ដោយមានលើកហេតុផលច្បាស់លាស់។ ពេលកុមារនៅផ្ទះ បើឪពុកម្តាយមិនប្រកាន់នូវរបៀបរស់នៅបែបប្រជាធិបតេយ្យនេះ កុមារពិតជាមានការលំបាក។

ពេលវេលាសម្រាប់ធ្វើការងារអប់រំកុមារចែកចេញជាៈ

- ពេលវេលាសម្រាប់អប់រំកុមារដោយផ្ទាល់ មានចំនួន៨០ភាគរយ និង
- ដោយប្រយោល២០ភាគរយ។ ២០ភាគរយនៃពេលវេលានេះ គ្រូនិងអ្នកអាណាព្យាបាលសិស្ស ត្រូវការសម្រាប់ធ្វើទំនាក់ទំនងគ្នាជាប់ជានិច្ច ដើម្បីផ្តល់ពត៌មានគ្នាទៅវិញទៅមក។ ដូចនេះសមត្ថភាពប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម គ្រូត្រូវមានជាដាច់ខាត។ មួយវិញទៀតការងាររៀបចំមេរៀនសម្រាប់បង្រៀនសិស្ស និងប្រជុំការងាររដ្ឋបាល ព្រមទាំងបច្ចេកទេសក៏រាប់ចូលក្នុងការងារប្រយោលដែរ។

## គុណវិបត្តិ/ការលំបាក

អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលមានគុណវិបត្តិដូចខាងក្រោមៈ

- ពេលកុមារអង្គុយជាក្រុម នៅបែកពីគ្នា គ្រូអាចមើលការខុសត្រូវមិនបានគ្រប់ជ្រុងជ្រោយ
- នៅក្នុងថ្នាក់រៀន កុមារតែងតែជជែក ពិភាក្សា រួមទាំងចំនួនកុមារលើសនិយាមគរុកោសល្យ ធ្វើឱ្យមានសំឡេងលឺពេញថ្នាក់ ពេលខ្លះរហូតដល់បាត់បង់សណ្តាប់ធ្នាប់
- បើគ្រូមិនមានពេលគ្រប់គ្រាន់ គ្រូនឹងពិបាកក្នុងការសម្រេចផែនការតាមមុខវិជ្ជានីមួយៗ ដែលបានកំណត់ និងរំពឹងទុកពីថ្នាក់ជាតិ។ល។

## តារាងទី២ គុណសម្បត្តិនិងការលំបាក នៃគោលវិធីគ្រូ និងសិស្សមជ្ឈមណ្ឌល

| លក្ខណៈសម្បត្តិ | គោលវិធីគ្រូមជ្ឈមណ្ឌល | គោលវិធីសិស្សមជ្ឈមណ្ឌល |
|---|---|---|
| គុណសម្បត្តិ និងភាពងាយស្រួល | **អនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌល គ្រូ៖**<br>- ងាយសម្រេចគោលដៅនៃការសិក្សាថ្នាក់ជាតិ ទាំងខ្លឹមសារ និងពេលវេលា<br>- ងាយគ្រប់គ្រងវិន័យក្នុងថ្នាក់ ទោះចំនួនកុមារលើសពីនិយាមគរុកោសល្យបន្តិចបន្តួចក៏ដោយ<br>- អាចផ្តល់ និងចែករំលែកចំណេះដឹងបានច្រើនក្នុងរយៈពេលខ្លី។ តែមិនប្រាកដថា កុមារយល់និងអាចយកចំណេះដឹងនេះយកទៅអនុវត្តបានជោគជ័យប៉ុណ្ណោះទេ<br>- ត្រូវការប្រើប្រាស់សម្ភារៈឧបទេសតិច<br>- ប្រើសម្រាប់គ្រូរំលឹកមេរៀនត្រៀមមុនពេលកុមារប្រឡង<br>- អាចបង្រៀនកុមារ ដើម្បីផ្តល់ចំណេះដឹងបានដែរ ទោះជា | **អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូ៖**<br>- ជាអ្នកសម្របសម្រួលឱ្យកុមាររៀនសូត្រ សហការរៀនសូត្រ មិននិយាយច្រើនតែម្នាក់ឯង ។<br>- ទទួលបានការពង្រឹងសមត្ថភាពសំខាន់មួយទៀត គឺបំណិនសង្កេត<br>- បន្តការអភិវឌ្ឍចំណេះដឹងរហូតពេញមួយជីវិត ត្រៀមខ្លួនបានល្អ ឆ្លើយបានរាល់សំណួរ ព្រមទាំងចម្ងល់របស់កុមារ<br>- គ្រូទទួលបានបទពិសោធន៍ និងចំណេះដឹងថ្មីៗពីកុមារទៀតផង។<br>**គុណសម្បត្តិធំធេងនៃការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានទៅលើកុមារ៖**<br>- កុមារពេញចិត្ត ស្រឡាញ់ការសិក្សា ព្រោះចំណង់ |

| | | |
|---|---|---|
| | គ្រូបានទទួលការអប់រំគរុកោសល្យ បន្តិចបន្តួច។ល។<br>**អនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌលកុមារៈ**<br>- ធ្វើកិច្ចការសាលា និងដោះស្រាយបញ្ហាម្នាក់ៗឯង<br>- សមត្ថភាព អត់ធ្មត់ ភាពឯករាជ្យម្ចាស់ការ ស្វ័យសិក្សា និងធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងត្រូវបានអប់រំ និងពង្រឹង។ល។ | ចំណូលចិត្ត តម្រូវការ ព្រមទាំងសមត្ថភាពកុមារមានស្រាប់ ត្រូវបានគិតគូ និងយកចិត្តទុកដាក់<br>- ក្រៅពីរៀនចំណេះដឹងនិងជំនាញតាមរយៈការរៀនលេងជាក្រុម ធ្វើកិច្ចការជាក្រុម អនុវត្តគម្រោងសមត្ថភាពឬជំនាញទន់របស់កុមារជាច្រើនត្រូវបានពង្រឹង ដូចជាការប្រាស្រ័យទាក់ទងនិងសមត្ថភាពសហការ ចាត់ចែង សង្កេត វិភាគ ត្រិះរិះ ពិចារណា សម្រេចចិត្ត ដោះស្រាយបញ្ហា ប្រកបដោយស្មារតីទទួលខុសត្រូវ<br>- ពេលកុមារពេញចិត្តស្រឡាញ់ការសិក្សា បំណិនស្វ័យសិក្សាកុមារត្រូវបានលើកស្ទួយ កុមារចេះធ្វើការសិក្សាស្រាវជ្រាវ ហ៊ានសួរបង្កើតចម្ងល់<br>- កុមាររៀនមានទំនាក់ទំនងសង្គមបានល្អ មានជំនឿជឿ |

| | | |
|---|---|---|
| | | ដាក់លើសមត្ថភាពខ្លួនឯង កាត់បន្ថយការភ័យខ្លាច ក្លាហានចេះធ្វើអ្វីៗជាច្រើនដោយខ្លួនឯង និងដោះស្រាយបញ្ហា។ល។ |
| **គុណវិបត្តិនិងផលវិបាក** | អនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌល<br>- សមត្ថភាពមានស្រាប់ និងតម្រូវការរបស់កុមារ មិនត្រូវបានយកចិត្តទុកដាក់ ជាមូលហេតុកុមារបាត់បង់នូវសមត្ថភាពចង់ចង់ដឹង និងស្រឡាញ់ការសិក្សា។<br>- ការអប់រំជំនាញទន់ ដល់កុមារមានកម្រិតតិចបំផុត។ កុមារទទួលបានឱកាសតិចបំផុត ក្នុងការសួរសំណួរ ជជែកពិភាក្សាជាមួយមិត្តរួមថ្នាក់ឱ្យជួយបំភ្លឺ បកស្រាយចម្ងល់ បញ្ចេញមតិយោបល់តាមរយៈភាពទន់ខ្សោយក្នុងការចូលរួមផ្តល់គំនិត បទពិសោធធ្វើការងារជាក្រុម ប្រាស្រ័យទាក់ទង ពេលកុមារត្រូវចូលទៅរស់នៅក្នុង | ចំនួនកុមារច្រើនលើសលប់ពីនិយាម ថ្នាក់រៀនតូច សម្ភារៈឧបទ្ទេសមិនគ្រប់គ្រាន់ជាមូលហេតុនៃការលំបាកៈ<br>- ពេលកុមារអង្គុយ ជាក្រុមនៅបែកពីគ្នា គ្រូអាចមើលការខុសត្រូវមិនបានគ្រប់ជ្រុងជ្រោយ<br>- នៅក្នុងថ្នាក់រៀន កុមារតែងតែជជែក ពិភាក្សា រួមទាំងចំនួនកុមារលើសនិយាមគរុកោសល្យ ធ្វើឱ្យមានសំឡេងឮពេញថ្នាក់ ពេលខ្លះរហូតដល់បាត់បង់សណ្តាប់ធ្នាប់<br>- បើគ្រូមិនមានពេលគ្រប់គ្រាន់ គ្រូនឹងពិបាកក្នុងការសម្រេចផែនការតាមមុខវិជ្ជានីមួយៗ ដែលបានកំណត់ |

| | | |
|---|---|---|
| | សង្គមធំ កុមារអាចមានការលំបាក កុមារមិនហ៊ានផ្តល់មតិយោបល់ប្រកបដោយហេតុផល និងស្មារតីទទួលខុសត្រូវ កុមាររង់ចាំតែធ្វើតាមការណែនាំ បាត់បង់និងលែងមានឆន្ទៈបណ្តុះនិងបង្កើតគំនិតខ្លួនឯង មិនមានភាពឯករាជ្យម្ចាស់ការ។ល។ | និងរំពឹងទុកពីថ្នាក់ជាតិ។ល។ |

## ៩- គំរូទម្រង់កិច្ចតែងការបង្រៀនតាមមុខវិជ្ជា

## ឧទាហរណ៍ ទម្រង់កិច្ចតែងការបង្រៀន

កាលបរិច្ឆេទ (ថ្ងៃត្រូវបង្រៀន) ៖.......................................................

ថ្នាក់កម្រិត៖..........................................................................

មុខវិជ្ជា៖.............................................................................

ប្រធានបទ៖.........................................................................

ខ្លឹមសារ៖...........................................................................

សកម្មភាពគោល៖...................................................................

ចំណងជើងមេរៀន៖...............................................................

រយៈពេល៖.........................................................................

### ក- វត្ថុបំណង/លទ្ធផលរំពឹងទុក៖

- វិជ្ជាសម្បទា៖.........................................................
- បំណិនសម្បទា៖......................................................
- ចរិយាសម្បទា៖.......................................................

## ខ- សម្ភារឧបទេស និងការរៀបចំ៖

- សម្ភារឧបទេស៖
  - ✓ សម្ភារៈគ្រូ៖.............................................................
  - ✓ សម្ភារៈកុមារ៖.........................................................
- ការរៀបចំ
  - ✓ ទីកន្លែង៖..............................................................
  - ✓ ការរៀបចំកុមារ៖......................................................
- គោលវិធី៖....................................................................

## គ- ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពកុមារ |
|---|---|---|
| | **ជំហានទី១៖** លំនឹងថ្នាក់ (វត្តមាន អនាម័យ ប្រមូលអារម្មណ៍ | |
| | **ជំហានទី២៖** រំឭកមេរៀនចាស់ ទំនាក់ទំនងមេរៀនថ្មី | |
| | **ជំហានទី៣៖** មេរៀនថ្មី (ចំណងជើងមេរៀន) អនុវត្តតាមលំនាំបង្រៀននិងរៀនទៅតាមសកម្មភាពគោលនៃមុខវិជ្ជានីមួយៗ | |
| | **ជំហានទី៤៖** ពង្រឹងចំណេះដឹង | |
| | **ជំហានទី៥៖** បណ្តាំផ្ញើ កិច្ចការផ្ទះ | |

ថ្ងៃ.................. ទី......... ខែ........ ឆ្នាំ....... ព.ស..............

**គ្រូប្រចាំថ្នាក់**

ហត្ថលេខានិងឈ្មោះ

## ១០- សង្ខេបខ្លឹមសាររបស់សៀវភៅ

ដើម្បីក្លាយជាពលរដ្ឋពេញលេញសតវត្សទី២១ ពលរដ្ឋម្នាក់ៗដាច់ខាត ត្រូវទទួលបានការអប់រំពេញមួយជីវិត លើជំនាញទាំងពីរ ទាំងជំនាញរឹងនិងជំនាញទន់ ឬលើសម្បទាទាំងបី រួមមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ប្រកបដោយតុល្យភាព។

អប់រំជំនាញទន់ដល់កុមារ ក្នុងបំណងនិងជាគុណប្រយោជន៍ ឱ្យកុមារមានភាពប៉ិនប្រសប់និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ជំនាញរឹង ឬចំណេះដឹង និងមានចរិយាល្អ រស់នៅប្រកបដោយសុខដុមនីយកម្មជាមួយគ្នាក្នុងសង្គម។

ការអប់រំជំនាញទន់នេះពិតជាមិនមានភាពងាយស្រួលនោះទេ តម្រូវឱ្យអ្នកអប់រំ មានការអត់ធ្មត់ និងចាប់ផ្តើមជាមួយកុមារតាំងពីកុមារនៅតូច។

ក្រៅពីសមត្ថភាពក្នុងការផ្ទេរចំណេះដឹង អ្នកដែលមានអាជីពអ្នកអប់រំ ជាគ្រូបង្រៀន ត្រូវមានសមត្ថភាពជាច្រើនទៀត រួមមានសមត្ថភាពក្នុងការសង្កេត ដើម្បីងាយស្គាល់ពីសមត្ថភាពកុមារមានស្រាប់ និងសមត្ថភាព ស្រឡាញ់ការសិក្សាពេញមួយជីវិតសម្រាប់ត្រៀមខ្លួនបានល្អអាចឆ្លើយតបនិងបកស្រាយរាល់ចម្ងល់កុមារបានដោយងាយ។ល។

មួយវិញទៀត អ្នកដែលមានអាជីពជាគ្រូបង្រៀន ត្រូវដឹងច្បាស់ថា ថាពេលណាត្រូវប្រើគោលវិធីគ្រូមជ្ឈមណ្ឌលនិងពេលណាប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីឱ្យកុមារទទួលបានការអប់រំ លើជំនាញទាំងពីរ ទាំងជំនាញរឹងនិងជំនាញទន់ ឬលើសម្បទាទាំងបី រួមមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ប្រកបដោយតុល្យភាព ក្លាយជាពលរដ្ឋពេញលេញក្នុងសតវត្សទី២១៕

# ឯកសារពិគ្រោះ


- ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ភ្នំពេញ ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ នាយកដ្ឋានអប់រំកុមារតូច ភ្នំពេញ ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា១២+២ បោះពុម្ពឆ្នាំ ២០១៣។
- ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានកុមារតូច កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា (កុមារអាយុ៥ឆ្នាំ) បោះពុម្ពឆ្នាំ២០០៩។
- ក្រសួងអប់រំ យុវជន និងកីឡា និង សមាគមគ្រួសារយើង គំនូសនិងការត្រៀមកុមារឱ្យហាត់សរសេរ ផ្នែកមត្តេយ្យសិក្សា បោះពុម្ពដោយអង្គការកុមារកម្ពុជា ឆ្នាំ ១៩៩៥។
- ក្រសួងអប់រំ យុវជន និងកីឡា គំនូសនិងការត្រៀមកុមារឱ្យហាត់សរសេរ ផ្នែកមត្តេយ្យសិក្សា (ឯកសារឧបសម្ព័ន្ធ) បោះពុម្ពដោយអង្គការកុមារកម្ពុជា ឆ្នាំ ២០១៥។
- ក្រសួងអប់រំ យុវជន និងកីឡា តន្ត្រីនិងចំរៀង ផ្នែកមត្តេយ្យសិក្សាសម្រាប់គ្រូមត្តេយ្យ បោះពុម្ពដោយ ឆ្នាំ ១៩៩៩។
- ក្រសួងអប់រំ យុវជន និងកីឡា គណិតវិទ្យានៅមត្តេយ្យសិក្សា បោះពុម្ពដោយអង្គការកុមារកម្ពុជា ឆ្នាំ១៩៩៨។
- ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានអប់រំកុមារតូច បទពិសោធន៍ល្អៗក្នុងការអនុវត្តការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅកម្ពុជា បោះពុម្ពឆ្នាំ២០០៦។
- ក្រសួងអប់រំ យុវជន និងកីឡា ចិត្តចលភាព ផ្នែកមត្តេយ្យសិក្សា បោះពុម្ពដោយអង្គការកុមារកម្ពុជា ឆ្នាំ១៩៩៧។
- អង្គការកុមារកម្ពុជា កំរងអត្ថបទ ល្បែងចលនាម្រាមដៃសម្រាប់កុមារា កុមារី។

បោះពុម្ព ឆ្នាំ២០២១
ចំនួន ៣ ០០០ ក្បាល
**ដោយ មូលនិធិ** Knorr-Bremes Global Care

KNORR-BREMSE global care

អប់រំសមត្ថភាពចាំបាច់ ដល់កុមារមត្តេយ្យ

២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អប់រំ សមត្ថភាពចាំបាច់

## ដល់កុមារមត្តេយ្យសិក្សា និងសិស្សបឋមសិក្សា




មូលនិធិ
KNORR-BREMSE global care
តាមរយៈ
tkg THÜRINGISCH KAMBODSCHANISCHE GESELLSCHAFT e.V.
COMPED

ឆ្នាំ ២០២១